18K-CA083-東埔寨巴利文：巴利語翻譯與字詞分析指南-字.pdf 1 2019/8/5 下午 03:19:42

# របៀប
# ប្រែនិងសម្ពន្ធវិគ្គហៈ

ក្នុងបាលីវេយ្យាករណ៍

**សម្រាប់សាលាពុទ្ធិកបឋមសិក្សា**


ព្រះធម្មឃោសាចារ្យ **សេខ នាង**

អគ្គាធិការរងនៃពុទ្ធិកសិក្សា

និងជាសាស្ត្រាចារ្យនៅពុទ្ធិកសាកលវិទ្យាល័យ



ភ្នំពេញ

**ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ**

**បោះពុម្ពចែកជាធម្មទាន**

ព.ស. ២៥៦៣ គ.ស. ២០១៩


CA083 របៀបប្រែនិងសម្ពន្ធវិគ្គហៈ Tips for translation and connection of Viggaha

As this is a Dhamma text,
we request that it be treated with respect.
If you are finished with it,
please pass it on to others or
offer it to a monastery, school or public library.
Thanks for your co-operation.
**Namo Amitabha!**


《東埔寨巴利文：巴利語翻譯與字詞分析指南
Tips for translation and connection of Viggaha》

財團法人佛陀教育基金會 印贈
Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Website: www.budaedu.org ; overseas@budaedu.org,
**This book is for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
CA083

ព្រះធម្មឃោសាចារ្យ **សេខ នាង**

អគ្គាធិការរងនៃពុទ្ធិកសិក្សា

និងជាសាស្ត្រាចារ្យនៅពុទ្ធិកសាកលវិទ្យាល័យ

# របៀប

# ប្រែនិងសម្ពន្ធវិគ្គហៈ

ក្នុងបាលីវេយ្យាករណ៍

## សម្រាប់សាលាពុទ្ធិកបឋមសិក្សា

មាន

-សមាសនិទ្ទេស

-តទ្ធិតនិទ្ទេស

-កិតកនិទ្ទេស

-ឧណាទិនិទ្ទេស

**ភ្នំពេញ**

**ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ**

**បោះពុម្ពចែកជាធម្មទាន**

**ព.ស. ២៥៦៣** **គ.ស. ២០១៩**

# អារម្ភកថា

របៀបប្រែ និងសម្ពន្ធវិគ្គហៈក្នុងបាលីវេយ្យាករណ៍ មានច្រើនបែបផ្សេងៗ គ្នា ។ ឯរបៀបតទៅនេះ ខ្ញុំបានរៀបរៀងឡើង ក្នុងគោលបំណងដើម្បីសម្រាលដល់គ្រូនិងសិស្ស ដែលលំបាកចំពោះការសិក្សាបាលីវេយ្យាករណ៍ផង ដើម្បីឲ្យមានឯកភាពផង ។

របៀបប្រែនិងសម្ពន្ធនេះ នឹងបានជាគ្រឹះមួយដ៏សំខាន់ ធ្វើឲ្យងាយរិះរកយកមកលម្អិតស័ព្ទ ដែលនៅក្នុងគម្ពីរធម្មបទ ស្របតាមគោលបំណងកម្មវិធីភាសាបាលី ក្នុងពុទ្ធិកបឋមសិក្សា ។

ខ្ញុំបានរៀបចំចាត់ឲ្យទាលរ៉ូណេអូ ចែកម្តងរួចទៅហើយ ប៉ុន្តែ ពុំធូនល្មមដល់សេចក្តីត្រូវការ នៃសិក្ខាកាមសោះ ទើបខ្ញុំប្រគល់ឲ្យលោកចាន់ សយ ចាត់ការបោះពុម្ពផ្សាយ ដើម្បីស្របតាមបំណងអ្នកសិក្សាតទៅ ។

វត្តឧណ្ណាលោម, ថ្ងៃទី ៩ តុលា ព.ស. ២៥១៥ / គ.ស. ១៩៧១

ព្រះធម្មឃោសាចារ្យ

**សេខ នាង**

# របៀប

## ប្រែលោតប្រយោគនិងសម្ពន្ធក្នុងវិគ្គហៈនៃសមាស

***វិសេសនបុព្វបទ*** ឧ. មហន្តោ បុរិសោ = មហាបុរិសោ ។

### ប្រែលោតប្រយោគ

បុរិសោ *វីបុរស* មហន្តោ *ធំ* មហាបុរិសោ *ឈ្មោះមហាបុរិសោ*, មហាបុរិសោ *វីបុរសធំ* ។

### សម្ពន្ធ

មហន្តោ *វិសេសនៈរបស់* បុរិសោ ៗ *លិង្គត្ថៈ*, មហាបុរិសោ *សមាសនាមបទឈ្មោះ វិសេសនបុព្វបទកម្មធារយលុត្តសមាស ហើយជា* (*ឬនិង៍ជាលិង្គត្ថៈ*) ។

※※※

***វិសេសនុត្តរបទ*** ឧ. បុរិសោ ឧត្តមោ = បុរិសុត្តមោ ។

### ប្រែលោតប្រយោគ

បុរិសោ *វីបុរស* ឧត្តមោ *ដ៏ខ្ពង់ខ្ពស់* បុរិសុត្តមោ *ឈ្មោះបុរិសុត្តមោ*, បុរិសុត្តមោ *វីបុរសខ្ពង់ខ្ពស់* ។

### សម្ពន្ធ

ឧត្តមោ *វិសេសនៈរបស់* បុរិសោ ៗ *លិង្គត្ថៈ*, បុរិសុត្តមោ *សមាសនាមបទឈ្មោះវិសេសនុត្តរបទកម្មធារយលុត្តសមាស ហើយជា លិង្គត្ថៈ* ។

※※※

***វិសេសនោភយបទ*** ឧ. សីតញ្ច ឧណ្ហញ្ច = សីតុណ្ហំ (ឞានំ) ។

### ប្រែលោតប្រយោគ

(យំ ឞានំ *វីទីឯណា*) សីតំ ច *ត្រជាក់ផង* ឧណ្ហំ ច *ក្តៅផង* (តំ ឞានំ *វីទីនោះ*) សីតុណ្ហំ *ឈ្មោះសីតុណ្ហំ*, (ឞានំ *វីទី*) សីតុណ្ហំ *ទាំងត្រជាក់ទាំងក្តៅ* ។

### សម្ពន្ធ

យំ *វិសេសនៈរបស់* ឞានំ ៗ *លិង្គត្ថៈ*, ច *ទាំងពីរសព្ទបទបូរណៈក្នុងសីតំ* ឧណ្ហំ, សីតំ ឧណ្ហំ *វិសេសនៈរបស់* ឞានំ, តំ *វិសេសនៈរបស់*ឞានំ, សីតុណ្ហំ *សញ្ញាវិសេសនៈរបស់* ឞានំ ៗ *សញ្ញីវិសេសយៈ ហើយជា* (និងជា) *លិង្គត្ថៈ*, សីតុណ្ហំ *សមាសនាមបទឈ្មោះវិសេសនោភយបទកម្មធារយលុត្តសមាស ហើយជា*(និងជា) *វិសេសនៈរបស់* ឞានំ ៗ *លិង្គត្ថៈ* ។

📖❋❋

***ឧបមាបុព្វបទ*** ឧ. សង្ខំ ឥវ បណ្ឌរំ = សង្ខបណ្ឌរំ (ខីរំ) ។

ទិព្វំ ឥវ បក្ខុ = ទិព្វបក្ខុ ។

### ប្រែលោតប្រយោគ

(យំ ខីរំ *វីទឹកដោះស្រស់ឯណា*) បណ្ឌរំ *ស* សង្ខំ ឥវ *ដូចជាស័ង្ខ* (តំ ខីរំ *វីទឹកដោះស្រស់នោះ*) សង្ខបណ្ឌរំ *ឈ្មោះសង្ខបណ្ឌរំ*, (ខីរំ *វីទឹក*

ដោះស្រស់) សង្ខបណ្ឌរំ សដូចជាស័ង្ខ ។

ចក្ខុ រីភ្នែក ទិព្វំ ឥវ ដូចជាទិព្វ, ទិព្វចក្ខុ ឈ្មោះទិព្វចក្ខុ, ទិព្វចក្ខុ រីភ្នែក ដូចជាទិព្វ ។

## សម្ពន្ធ

យំ វិសេសនៈរបស់ ធីរំ ៗ លិង្គត្ថៈ, ឥវ សព្ទឧបមាជោតកៈក្នុង សង្ខំ ៗ ឧបមាវិសេសនៈរបស់ បណ្ឌរំ ៗ វិសេសនៈរបស់ ធីរំ, តំ វិសេសនៈរបស់ ធីរំ, សង្ខ-បណ្ឌរំ សញ្ញាវិសេសនៈរបស់ ធីរំ ៗ សញ្ញីវិសេសយៈហើយជា (និងជា) លិង្គត្ថៈ, សង្ខបណ្ឌរំ សមាសនាមបទឈ្មោះឧបមាបុព្វបទកម្មធារយលុត្តសមាស ហើយជា (និងជា) វិសេសនៈរបស់ ធីរំ ៗ លិង្គត្ថៈ ។ ឥវ សព្ទឧបមាជោតកៈក្នុង ទិព្វំ ៗ ឧបមាវិសេសនៈរបស់ ចក្ខុ ៗ លិង្គត្ថៈ, ទិព្វចក្ខុ សមាសនាមបទឈ្មោះឧបមាបុព្វបទកម្មធារយលុត្តសមាស ហើយជា (និងជា) លិង្គត្ថៈ ។

***ឧបមានុត្តរបទ*** ឧ. នរោ សីហោ ឥវ = នរសីហោ ។

## ប្រែលោតប្រយោគ

នរោ រីនរៈ សីហោ ឥវ ដូចជាសត្វសីហៈ នរសីហោ ឈ្មោះនរសីហោ, នរសីហោ រីនរៈដូចជាសត្វសីហៈ ។

## សម្ពន្ធ

ឥវ *សព្ទឧបមាជោតកៈក្នុង* សីហោ ៗ *ឧបមាវិសេសនៈរបស់* ឥវោ ៗ *លិង្គត្ថៈ*, ឥវសីហោ *សមាសនាមបទឈ្មោះឧបមានុត្តរបទកម្មធារយលុត្តសមាស ហើយជា*(និងជា)*លិង្គត្ថៈ* ។

📖❁❁

***សម្ភាវនបុព្វបទ*** ឧ. ខត្តិយោ (អហំ) ឥតិ មាតោ = ខត្តិយមាតោ ។

## ប្រែលោតប្រយោគ

មាតោ *វីមានះ* ខត្តិយោ អហំ ឥតិ *ថាអញជាក្សត្រិយ៍* ខត្តិយមាតោ *ឈ្មោះខត្តិយមានោ*, ខត្តិយមាតោ *វីមានះថាអញជាក្សត្រិយ៍* ។

## សម្ពន្ធ

ខត្តិយោ អហំ *សរូបនិទស្សនៈក្នុង* ឥតិ ៗ *សព្ទ សរូបនិទស្សនីយៈ ហើយជា* (និងជា) *សម្ភាវនៈក្នុង*មាតោ ៗ *លិង្គត្ថៈ*, ខត្តិយមាតោ *សមាសនាមបទឈ្មោះសម្ភាវនបុព្វបទកម្មធារយលុត្តសមាស ហើយជា*(និងជា)*លិង្គត្ថៈ* ។

📖❁❁

***អវធារណបុព្វបទ*** ឧ. ពុទ្ធោ ឯវ រតនំ = ពុទ្ធរតនំ ។

## ប្រែលោតប្រយោគ

រតនំ *វីកែវ* ពុទ្ធោ ឯវ *គឺព្រះពុទ្ធ* ពុទ្ធរតនំ *ឈ្មោះពុទ្ធរតនំ*, ពុទ្ធរតនំ *វីកែវគឺព្រះពុទ្ធ* ។

## សម្ពន្ធ

ឯវ *សព្ទអវធារណៈក្នុង* ពុទ្ធោ ។ *នានាលិង្គត្ថវិសេសនៈរបស់* រតនំ ។ *លិង្គត្ថៈ*, ពុទ្ធរតនំ *សមាសនាមបទឈ្មោះអវធារណបុព្វបទកម្មធារយលុត្តសមាស ហើយជា(និងជា)លិង្គត្ថៈ* ។

📖❀❀

***សមាហារទិគុ*** ឧ. តយោ លោកា = តិលោកំ ។

## ប្រែលោតប្រយោគ

លោកា *វីលោកទ*. តយោ *បី* តិលោកំ *ឈ្មោះតិលោកំ*, តិលោកំ *វីលោកបី* ។

## សម្ពន្ធ

តយោ *វិសេសនៈរបស់* លោកា ។ *លិង្គត្ថៈ*, តិលោកំ *សមាសនាមបទឈ្មោះសមាហារទិគុលុត្តសមាស ហើយជា(និងជា)លិង្គត្ថៈ* ។

📖❀❀

***អសមាហារទិគុ*** ឧ. ឯកោ បុគ្គលោ = ឯកបុគ្គលោ ។

## ប្រែលោតប្រយោគ

បុគ្គលោ *វីបុគ្គល* ឯកោ *ម្នាក់* ឯកបុគ្គលោ *ឈ្មោះឯកបុគ្គលោ*, ឯកបុគ្គលោ *វីបុគ្គលម្នាក់* ។

## សម្ពន្ធ

ឯកោ *វិសេសនៈរបស់* បុគ្គលោៗ *លិង្គត្ថៈ*, ឯកបុគ្គលោ *សមាសនាមបទ ឈ្មោះអសមាហារទិគុលុត្តសមាស ហើយជា(និងជា)លិង្គត្ថៈ ។*

📖❋❋

***ទុតិយាតប្បុរិស***: ឧ. សុខំ បត្តោ = សុខប្បត្តោ (ជនោ) ។

## ប្រែលោតប្រយោគ

(យោ ជនោ *វីជនឯណា*) បត្តោ *ដល់ហើយ* សុខំ *នូវសុខ*, (សោ ជនោ *វីជននោះ*) សុខប្បត្តោ *ឈ្មោះសុខប្បត្តោ* (ជនោ *វីជន*) សុខប្បត្តោ *ដល់ហើយនូវសុខ* ។

### សម្ពន្ធ

យោ *វិសេសនៈរបស់* ជិតោ ៗ *លិង្គត្ថៈ*, សុខំ *អវុត្តកម្មក្នុង* បត្តោៗ *វិសេសនៈរបស់* ជិតោ, សោ *វិសេសនៈរបស់* ជិតោ, សុខប្បត្តោ *សញ្ញាវិសេសនៈរបស់* ជិតោ ៗ *សញ្ញីវិសេសយៈ ហើយជា* (*និងជា*) លិង្គត្ថៈ, សុខប្បត្តោ *សមាសនាមបទឈ្មោះទុតិយាតប្បុរិសលុត្តសមាស ហើយជា*(*និងជា*)*វិសេសនៈរបស់* ជិតោៗ *លិង្គត្ថៈ* ។

📖❋❋

***តតិយាតប្បុរិស***: ឧ. សល្លេន វិទ្ធោ = សល្លវិទ្ធោ (មិគោ) ។

### ប្រែលោតប្រយោគ

(យោ មិគោ *វីម្រឹគឯណា*) សល្លេន *ដែលសរ* វិទ្ធោ *មុតហើយ* (សោ មិគោ *វីម្រឹគនោះ*) សល្លវិទ្ធោ *ឈ្មោះសល្លវិទ្ធោ* (មិគោ *វីម្រឹគ*) សល្លវិទ្ធោ *ដែលសរមុតហើយ ឬថា* (យោ មិគោ *វីម្រឹគឯណា*) វិទ្ធោ *ដែលព្រានបាញ់ហើយ* សល្លេន *ដោយសរ* (សោ មិគោ *វីម្រឹគនោះ*) សល្លវិទ្ធោ *ឈ្មោះសល្លវិទ្ធោ* (មិគោ *វីម្រឹគ*) សល្លវិទ្ធោ *ដែលព្រានបាញ់ហើយដោយសរ* ។

### សម្ពន្ធ

យោ *វិសេសនៈរបស់* មិគោៗ *លិង្គត្ថៈ*, សល្លេន *ករណៈក្នុង* វិទ្ធោ ៗ

*វិសេសនៈរបស់* មិគោ, សោ *វិសេសនៈរបស់* មិគោ, សល្លវិទ្ធោ *សញ្ញាវិសេសនៈរបស់* មិគោៗ *សញ្ញីវិសេសយៈ ហើយជា* (និង៍ជា) *លិង្គត្ថៈ*, សល្លវិទ្ធោ *សមាសនាមបទឈ្មោះតតិយាតប្បុរិសលុត្តសមាស ហើយជា* (និង៍ជា) *វិសេសនៈរបស់* មិគោៗ លិង្គត្ថៈ ។ *ឬថា* យោ *វិសេសនៈរបស់* មិគោៗ *លិង្គត្ថៈ*, សល្លេន *ករណៈក្នុង* វិទ្ធោៗ *វិសេសនៈរបស់* មិគោ, សោ *វិសេសនៈរបស់* មិគោ, សល្លវិទ្ធោ *សញ្ញាវិសេសនៈរបស់* មិគោៗ *សញ្ញីវិសេសយៈ ហើយជា* (និង៍ជា) *លិង្គត្ថៈ*, សល្លវិទ្ធោ *សមាសនាមបទឈ្មោះតតិយាតប្បុរិសលុត្តសមាស ហើយជា* (និង៍ជា) *វិសេសនៈរបស់* មិគោៗ *លិង្គត្ថៈ* ។

📖❊❊

***ចតុត្ថីតប្បុរិសៈ*** : ឧ. កឋិនស្ស ទុស្សំ = កឋិនទុស្សំ ។

**ប្រែលោតប្រយោគ**

ទុស្សំ *រីសំពត់* កឋិនស្ស *ដើម្បីកឋិន* កឋិនទុស្សំ *ឈ្មោះកឋិនទុស្សំ*, កឋិនទុស្សំ *រីសំពត់ដើម្បីកឋិន ។ ឬថា* ទុស្សំ *រីសំពត់* (អាគីតំ *ដែលជននាំមកហើយ*) កឋិនស្ស *ដើម្បីកឋិន* កឋិនទុស្សំ *ឈ្មោះកឋិនទុស្សំ*, កឋិនទុស្សំ *រីសំពត់ដែលជននាំមកហើយដើម្បីកឋិន ។*

**សម្ពន្ធ**

កឋិនស្ស *សម្បទានៈក្នុង* ទុស្សំ ៗ *លិង្គត្ថៈ*, កឋិនទុស្សំ *សមាសនាមបទ*

*ឈ្មោះចតុត្ថីតប្បុរិសលុត្តសមាស ហើយជា(និង៍ជា)លិង្គត្ថៈ ។ ឬថា* កបិនស្ស *សម្បទានៈក្នុង* អានីតំ។ *វិសេសនៈរបស់* ទុស្សំ ។ *លិង្គត្ថៈ*, កបិនទុស្សំ *សមាសនាមបទឈ្មោះចតុត្ថីតប្បុរិសលុត្តសមាស ហើយជា(និង៍ជា)លិង្គត្ថៈ ។*

📖❋❋

***បញ្ចមីតប្បុរិសៈ*** ឧ. រញ្ញោ ភយំ = រាជភយំ ។

## ប្រែលោតប្រយោគ

ភយំ *រីភ័យ* រញ្ញោ *អំពីស្តេច* រាជភយំ *ឈ្មោះរាជភយំ*, រាជភយំ *រីភ័យអំពីស្តេច ។*

## សម្ពន្ធ

រញ្ញោ *អបាទានៈក្នុង* ភយំ។ *លិង្គត្ថៈ*, រាជភយំ *សមាសនាមបទឈ្មោះបញ្ចមីតប្បុរិសលុត្តសមាស ហើយជា(និង៍ជា)លិង្គត្ថៈ ។*

📖❋❋

***ឆដ្ឋីតប្បុរិសៈ*** ឧ. រញ្ញោ បុត្តោ = រាជបុត្តោ ។

## ប្រែលោតប្រយោគ

បុត្តោ *រីកូន* រញ្ញោ *របស់ស្តេច* រាជបុត្តោ *ឈ្មោះរាជបុត្តោ*, រាជបុត្តោ *រីកូនរបស់ស្តេច ។*

### សម្ពន្ធ

*រញ្ញោ សាមិសម្ពន្ធក្នុង* បុត្តោ ។ *លិង្គត្ថៈ*, រាជបុត្តោ *សមាសនាមបទ ឈ្មោះឆដ្ឋីតប្បុរិសលុត្តសមាស ហើយជា(និងជា)លិង្គត្ថៈ ។*

📖❀❀

***សត្តមីតប្បុរិសៈ***   ឧ. *រូបេ* សញ្ញា = *រូបសញ្ញា* ។

### ប្រែលោតប្រយោគ

សញ្ញា *វីសេចក្តីសម្គាល់ រូបេ ក្នុងរូប រូបសញ្ញា ឈ្មោះរូបសញ្ញា, រូបសញ្ញា វីសេចក្តីសម្គាល់ក្នុងរូប ។*

### សម្ពន្ធ

*រូបេ វេសយិកាធារៈក្នុង* សញ្ញា ។ *លិង្គត្ថៈ*, *រូបសញ្ញា សមាសនាមបទ ឈ្មោះសត្តមីតប្បុរិសលុត្តសមាស ហើយជា(និងជា)លិង្គត្ថៈ ។*

📖❀❀

***ឧភយតប្បុរិសៈ***   ឧ. ន ព្រាហ្មណោ = អព្រាហ្មណោ  (អយំ  បុរិសោ) ។

ន  អរិយោ = អនរិយោ  (អយំ  មនុស្សោ) ។

## ប្រែលោតប្រយោគ

(អយំ បុរិសោ *រីបុរសនេះ*) ព្រាហ្មណោ *ជាព្រាហ្មណ៍* ន មិនមែន អព្រាហ្មណោ *ឈ្មោះអព្រាហ្មណោ*, (បុរិសោ *រីបុរស*) អព្រាហ្មណោ *ជាព្រាហ្មណ៍មិនមែន គឺមិនមែនជាព្រាហ្មណ៍* ។

(អយំ មនុស្សោ *រីមនុស្សនេះ*) អរិយោ *ជាអរិយៈ* ន មិនមែន អនរិយោ *ឈ្មោះអនរិយោ*, (មនុស្សោ *រីមនុស្ស*) អនរិយោ *ជាអរិយៈមិនមែន គឺមិនមែនអរិយៈ។ ឬប្រែមិនបាច់បញ្ចូលអញ្ញបទថា* ព្រាហ្មណោ *រីព្រាហ្មណ៍* ន មិនមែន អព្រាហ្មណោ *ឈ្មោះអព្រាហ្មណោ*, អព្រាហ្មណោ *រីព្រាហ្មណ៍មិនមែន គឺមិនមែនព្រាហ្មណ៍* ។ អរិយោ *រីអរិយៈ* ន មិនមែន អនរិយោ *ឈ្មោះអនរិយោ*, អនរិយោ *រីអរិយៈមិនមែន គឺមិនមែនអរិយៈ* ។

## សម្ពន្ធ

អយំ *វិសេសនៈរបស់* បុរិសោ។ *លិង្គត្ថៈ*, ន *សព្វបដិសេធក្នុង*ព្រាហ្មណោ។ *វិសេសនៈរបស់* បុរិសោ, អព្រាហ្មណោ *សមាសនាមបទឈ្មោះឧភយតប្បុរិសលុត្តសមាស ឬឈ្មោះនបុព្វបទកម្មធារយលុត្តសមាស ហើយជា* (និងជា) *សញ្ញាវិសេសនៈរបស់* បុរិសោ។ *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ* ។

អយំ *វិសេសនៈរបស់* មនុស្សោ ។ *លិង្គត្ថៈ*, ន *សព្វបដិសេធក្នុង* អរិយោ។ *វិសេសនៈរបស់* មនុស្សោ, អនរិយោ *សមាសនាមបទឈ្មោះឧភយតប្បុរិសលុត្តសមាស ហើយជា* (និងជា) *សញ្ញាវិសេសនៈរបស់* មនុស្សោ។ *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ* ។

ន *សព្ទបដិសេធក្នុង* ព្រាហ្មណោ *លិង្គត្ថៈ,* អព្រាហ្មណោ *សមាសនាមបទឈ្មោះឧភយតប្បុរិសលុត្តសមាស ហើយជា(និងជា) លិង្គត្ថៈ ។*

ន *សព្ទបដិសេធក្នុង* អរិយោ *លិង្គត្ថៈ,* អនរិយោ *សមាសនាមបទឈ្មោះឧភយតប្បុរិសលុត្តសមាស ហើយជា (និងជា) លិង្គត្ថៈ ។*

📖❋❋

***សមាហារទ្វន្ទៈ*** ឧ. សមថោ ច វិបស្សនា ច = សមថវិបស្សនំ ។

បណ្ណញ្ច បុប្ផញ្ច ផលញ្ច = បណ្ណបុប្ផផលំ ។

**ប្រែលោតប្រយោគ**

សមថោ ច *វីសមថៈផង* វិបស្សនា ច *វីវិបស្សនាផង* សមថវិបស្សនំ *ឈ្មោះសមថវិបស្សនំ,* សមថវិបស្សនំ *វីសមថៈ និងវិបស្សនា ។*

បណ្ណំ ច *វីស្លឹកផង* បុប្ផំ ច *វីផ្កាផង* ផលំ ច *វីផ្លែផង* បណ្ណបុប្ផផលំ *ឈ្មោះបណ្ណបុប្ផផលំ,* បណ្ណបុប្ផផលំ *វីស្លឹកនិងផ្កានិងផ្លែ ។*

**សម្ពន្ធ**

ច *ទាំងពីរសព្ទបទសមុច្ចយៈក្នុង* សមថោ វិបស្សនា, សមថោក្តី វិបស្សនាក្តី *លិង្គត្ថៈ,* សមថវិបស្សនំ *សមាសនាមបទឈ្មោះសមាហារទ្វន្ទលុត្តសមាសហើយជា(និងជា)លិង្គត្ថៈ ។*

ប *ទាំងបីសព្ទបទសមុច្ចយៈក្នុងបណ្ឌំ* បុប្ផំ ផលំ, បណ្ឌំក្តី បុប្ផំក្តី ផលំក្តី *លិង្គត្ថៈ*, បណ្ឌបុប្ផផលំ *សមាសនាមបទឈ្មោះសមាហារទ្វន្ទលុត្ត សមាស ហើយជា(និងជា)លិង្គត្ថៈ ។*

📖❋❋

***អសមាហារទ្វន្ទ:*** ឧ. សមណោ ច ព្រាហ្មណោ ច = សមណព្រាហ្មណា។

លាភោ ច សក្ការោ ច=លាភសក្ការោ ។

**ប្រែលោតប្រយោគ**

សមណោ ច *វីសមណៈផង* ព្រាហ្មណោ ច *វីព្រាហ្មណ៍ផង* សមណ-ព្រាហ្មណា *ឈ្មោះសមណព្រាហ្មណា*, សមណព្រាហ្មណា *វីសមណៈនិងព្រាហ្មណ៍ទាំងឡាយ* ។ លាភោ ច *វីលាភផង* សក្ការោ ច *វីសក្ការៈផង* លាភសក្ការោ *ឈ្មោះលាភសក្ការោ*, លាភសក្ការោ *វីលាភនិងសក្ការៈ ។*

**សម្ពន្ធ**

ច *ទាំងពីរសព្ទបទសមុច្ចយៈក្នុង* សមណោ ព្រាហ្មណោ, សមណោក្តី ព្រាហ្មណោក្តី *លិង្គត្ថៈ*, សមណព្រាហ្មណោ *សមាសនាមបទឈ្មោះអសមាហារទ្វន្ទលុត្តសមាស ហើយជា(និងជា)លិង្គត្ថៈ ។* ច *ទាំងពីរសព្ទបទសមុច្ចយៈក្នុង* លាភោ សក្ការោ, លាភោក្តី សក្ការោក្តី *លិង្គត្ថៈ*, លាភសក្ការោ *សមាសនាមបទឈ្មោះអសមាហារទ្វន្ទលុត្តសមាស ហើយជា(និងជា)លិង្គត្ថៈ ។*

📖❋❋

***ឧបសគ្គបុព្វក:*** ឧ. នគរស្ស សមីបំ = ឧបនគរំ ។

## ប្រែលោតប្រយោគ

សមីបំ *វីទីជិត* នគរស្ស *នៃនគរ* ឧបនគរំ *ឈ្មោះឧបនគរំ*, ឧបនគរំ *វីទីជិតនៃនគរ ។*

## សម្ពន្ធ

នគរស្ស *សាមិសម្ពន្ធៈក្នុងសមីបំៗ លិង្គត្ថៈ*, ឧបនគរំ *សមាសនាមបទ ឈ្មោះឧបសគ្គបុព្វកាព្យយីភាវលុត្តសមាសហើយជា(និងជា)លិង្គត្ថៈ។*

📖❈❈

***និបាតបុព្វក:*** ឧ. វុឌ្ឍានំ បដិបាដិ = យថាវុឌ្ឍំ ។

## ប្រែលោតប្រយោគ

បដិបាដិ *វីលំដាប់* វុឌ្ឍានំ *នៃជនចម្រើនទាំងឡាយ* យថាវុឌ្ឍំ *ឈ្មោះ យថាវុឌ្ឍំ*, យថាវុឌ្ឍំ *វីលំដាប់នៃជនចម្រើន។*

## សម្ពន្ធ

វុឌ្ឍានំ *សាមិសម្ពន្ធៈក្នុង* បដិបាដិៗ *លិង្គត្ថៈ*, យថាវុឌ្ឍំ *សមាសនាមបទឈ្មោះនិបាតបុព្វកាព្យយីភាវលុត្តសមាស ហើយជា(និងជា)លិង្គត្ថៈ ។*

📖❈❈

*ទុតិយាពហុព្វីហិឬទុតិយាតុល្យាធិករណពហុព្វីហិ* : ឧ. អាគតា សមណា យំ សោ = អាគតស្សមណោ (អារាមោ) ។

**ប្រែលោតប្រយោគ**

សមណា *វីសមណៈទ.* អាគតា *មកហើយ* យំ អារាមំ *កាន់អារាមឯណា* សោ អារាមោ *វីអារាមនោះ* អាគតស្សមណោ *ឈ្មោះអាគតស្សមណោ,* អារាមោ *វីអារាម* អាគតស្សមណោ *មានសមណៈមកហើយ ។*

**សម្ពន្ធ**

យំ *វិសេសនៈរបស់* អារាមំៗ *សម្បាបុណិយកម្មក្នុង* អាគតាៗ *វិសេសនៈរបស់* សមណាៗ *លិង្គត្ថៈ,* សោ *វិសេសនៈរបស់* អារាមោ, អាគតស្សមណោ *សញ្ញាវិសេសនៈរបស់* អារាមោៗ *សញ្ញីវិសេសយៈ ហើយជា* (និង*ជា*) *លិង្គត្ថៈ,* អាគតស្សមណោ *សមាសនាមបទឈ្មោះទុតិយាពហុព្វីហិ ឬ ឈ្មោះទុតិយាតុល្យាធិករណពហុព្វីហិលុត្តសមាសហើយជា* (និង*ជា*) *វិសេសនៈរបស់* អារាមោៗ *លិង្គត្ថៈ ។*

📖❋❋

*តតិយាពហុព្វីហិឬតតិយាតុល្យាធិករណពហុព្វីហិ* ឧ. ជិតានិ ឥន្ទ្រិយានិ យេន សោ = ជិតិន្ទ្រិយោ (សមណោ) ។

## ប្រែលោតប្រយោគ

ឥន្ទ្រិយានិ *វិឥន្ទ្រិយទ.* យេន សមណេន *គឺសមណៈ* (*ឬដែល សមណៈ*) *ឯណា* ជិតានិ *ឈ្នះហើយ,* សោ សមណោ *វិសមណៈ នោះ* ជិតិន្ទ្រិយោ *ឈ្មោះជិតិន្ទ្រិយោ,* សមណោ *វិសមណៈ* ជិតិន្ទ្រិយោ *មានឥន្ទ្រិយឈ្នះហើយ ។*

## សម្ពន្ធ

យេន *វិសេសនៈរបស់* សមណេន ៗ *អនភិហិតកត្តាក្នុង* ជិតានិៗ *វិសេសនៈរបស់* ឥន្ទ្រិយានិៗ *លិង្គត្ថៈ,* សោ *វិសេសនៈរបស់* សមណោ, ជិតិន្ទ្រិយោ *សញ្ញាវិសេសនៈរបស់* សមណោៗ *សញ្ញីវិសេសយៈហើយជា* (*និងជា*) *លិង្គត្ថៈ,* ជិតិន្ទ្រិយោ *សមាសនាមបទឈ្មោះតតិយាតុល្យាធិករណពហុព្វីហិលុត្តសមាស ហើយជា* (*និងជា*) *វិសេសនៈរបស់* សមណោៗ *លិង្គត្ថៈ ។*

***ចតុត្ថីពហុព្វីហិឬចតុត្ថីតុល្យាធិករណពហុព្វីហិ*** ឧ. ទិន្នោ សុង្កោ យស្ស សោ = ទិន្នសុង្កោ (រាជា) ។

## ប្រែលោតប្រយោគ

សុង្កោ *វិសួយ* ទិន្នោ *គឺអ្នកនគរថ្វាយហើយ* យស្ស រញ្ញោ *ដល់*

*ស្តេចឯណា,* សោ រាជា *រីស្តេចនោះ* ទិន្នសុង្កោ *ឈ្មោះទិន្នសុង្កោ*

រាជា *រីស្តេច* ទិន្នសុង្កោ *មានសួយគឺអ្នកនគរថ្វាយហើយ ។*

**សម្ពន្ធ**

យស្ស *វិសេសនៈរបស់* រញ្ញោៗ *សម្បទានៈក្នុង* ទិន្នោៗ *វិសេសនៈ*

*របស់* សុង្កោៗ *លិង្គត្ថៈ,* សោ *វិសេសនៈរបស់* រាជា, ទិន្នសុង្កោ *សញ្ញា*

*វិសេសនៈរបស់* រាជាៗ *សញ្ញីវិសេសយៈ ហើយជា* (*និងជា*) *លិង្គត្ថៈ,*

ទិន្នសុង្កោ *សមាសនាមបទឈ្មោះចតុត្ថីតុល្យាធិករណពហុព្វីហិលុត្តសមាស*

*ហើយជា* (*និងជា*) *វិសេសនៈរបស់* រាជាៗ *លិង្គត្ថៈ ។*

***បញ្ចមីពហុព្វីហិឬបញ្ចមីតុល្យាធិករណពហុព្វីហិ*** ឧ. និគ្គតា ជនា យស្មា

សោ = និគ្គតជនោ (គាមោ) ។

**ប្រែលោតប្រយោគ**

ជនា *រីជនទាំងឡាយ* និគ្គតា *ចេញហើយ* យស្មា គាមា *អំពីស្រុកណា*

សោ គាមោ *រីស្រុកនោះ* និគ្គតជនោ *ឈ្មោះនិគ្គតជនោ,* គាមោ *រីស្រុក*

និគ្គតជនោ *មានជនចេញហើយ ។*

## សម្ពន្ធ

យស្មា *វិសេសនៈរបស់* គាមាៗ *អបាទានៈក្នុង* និគ្គតាៗ *វិសេសនៈរបស់* ជនាៗ *លិង្គត្ថៈ,* សោ *វិសេសនៈរបស់* គាមោ, និគ្គតជនោ *សញ្ញាវិសេសនៈរបស់* គាមោៗ *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* និគ្គតជនោ *សមាសនាមបទឈ្មោះបញ្ចមីតុល្យាធិករណពហុព្វីហិលុត្តសមាស ហើយជា* (និងជា)*វិសេសនៈរបស់* គាមោៗ *លិង្គត្ថៈ ។*

📖❋❋

***ឆដ្ឋីពហុព្វីហិឬឆដ្ឋីតុល្យាធិករណពហុព្វីហិ*** ឧ. ខីណា អាសវា យស្ស សោ = ខីណាសវោ (ភិក្ខុ) ។

## ប្រែលោតប្រយោគ

អាសវា *វីអាសវៈទ.* យស្ស ភិក្ខុនោ *របស់ភិក្ខុឯណា* ខីណា *អស់ហើយ* សោ ភិក្ខុ *វីភិក្ខុនោះ* ខីណាសវោ *ឈ្មោះខីណាសវោ,* ភិក្ខុ *វីភិក្ខុ* ខីណាសវោ *មានអាសវៈអស់ហើយ ។*

## សម្ពន្ធ

យស្ស *វិសេសនៈរបស់* ភិក្ខុនោៗ *សាមិសម្ពន្ធក្នុង* អាសវាៗ *លិង្គត្ថៈ,* ខីណា *វិសេសនៈរបស់* អាសវា, សោ *វិសេសនៈរបស់* ភិក្ខុ, ខីណាសវោ

*សញ្ញាវិសេសនៈរបស់* ភិក្ខុ *សញ្ញីវិសេសយៈហើយជា* (និង៍ជា) *លិង្គត្ថៈ*, ទីណាសវោ *សមាសនាមបទឈ្មោះឆដ្ឋីតុល្យាធិករណពហុព្វីហិលុត្តសមាស ហើយជា*(និង៍ជា)*វិសេសនៈរបស់* ភិក្ខុ *លិង្គត្ថៈ* ។

📖❊❊

***សត្តមីពហុព្វីហិឬសត្តមីតុល្យាធិករណពហុព្វីហិ*** ឧ. សម្បន្នានិ សស្សានិ យស្មឹ សោ = សម្បន្នសស្សោ (ជនបទោ) ។

## ប្រែលោតប្រយោគ

សស្សានិ *វីសម្ទូង៍ទ*. សម្បន្នានិ *ដល់ព្រមហើយ* យស្មឹ ជនបទេ *ក្នុងជនបទឯណា*, សោ ជនបទោ *វីជនបទនោះ* សម្បន្នសស្សោ *ឈ្មោះសម្បន្នសស្សោ*, ជនបទោ *វីជនបទ* សម្បន្នសស្សោ *មានសម្ទូង៍ដល់ព្រមហើយ* ។

## សម្ពន្ធ

យស្មឹ *វិសេសនៈរបស់* ជនបទេៗ *វេសយិកាធារៈក្នុង* សម្បន្នានិៗ *វិសេសនៈរបស់* សស្សានិៗ *លិង្គត្ថៈ*, សោ *វិសេសនៈរបស់* ជនបទោ, សម្បន្នសស្សោ *សញ្ញាវិសេសនៈរបស់* ជនបទោៗ *សញ្ញីវិសេសយៈហើយជា* (និង៍ជា) *លិង្គត្ថៈ*, សម្បន្នសស្សោ *សមាសនាមបទឈ្មោះសត្តមីពហុព្វីហិឬឈ្មោះសត្តមីតុល្យាធិករណពហុព្វីហិលុត្តសមាស ហើយជា* (និង៍ជា) *វិសេសនៈរបស់* ជនបទោៗ *លិង្គត្ថៈ*ៗ

📖❊❊

***ឆដ្ឋីឧបមាពហុព្វីហិ*** ឧ. សុវណ្ណវណ្ណោ ឥវ វណ្ណោ យស្ស សោ = សុវណ្ណវណ្ណោ (តថាគតោ) ។

សុវណ្ណស្ស វិយ អស្ស វណ្ណោតិ = សុវណ្ណវណ្ណោ (តថាគតោ) ។

**ប្រែលោតប្រយោគ**

វណ្ណោ *រីសម្បុរ* យស្ស តថាគតស្ស *របស់តថាគតឯណា* សុវណ្ណវណ្ណោ ឥវ *ដូចជាសម្បុរនៃមាស,* សោ តថាគតោ *រីព្រះតថាគត នោះ* សុវណ្ណវណ្ណោ *ឈ្មោះសុវណ្ណវណ្ណោ,* តថាគតោ *រីព្រះតថាគត* សុវណ្ណវណ្ណោ *មានសម្បុរដូចជាសម្បុរនៃមាស។*

វណ្ណោ *រីសម្បុរ* អស្ស តថាគតស្ស *របស់ព្រះតថាគតនេះ* សុវណ្ណស្ស វណ្ណោ វិយ *ដូចជាសម្បុរនៃមាស ឬ* សុវណ្ណស្ស វិយ *ដូចមាស* ឥតិ *ព្រោះហេតុដូច្នោះ* សោ តថាគតោ *រីព្រះតថាគតនោះ* សុវណ្ណវណ្ណោ *ឈ្មោះសុវណ្ណវណ្ណោ,* តថាគតោ *រីព្រះតថាគត* សុវណ្ណវណ្ណោ *មានសម្បុរដូចជាសម្បុរនៃមាស ឬមានសម្បុរដូចមាស ។*

**សម្ពន្ធ**

ឥវ *សព្ទឧបមាជោតកៈក្នុង* សុវណ្ណវណ្ណោៗ *ឧបមាវិសេសនៈរបស់* វណ្ណោៗ *លិង្គត្ថៈ,* យស្ស *វិសេសនៈរបស់* តថាគតស្សៗ *សាមិសម្ពន្ធក្នុង* វណ្ណោ, សោ *វិសេសនៈរបស់* តថាគតោ, សុវណ្ណវណ្ណោ *សញ្ញាវិសេសនៈរបស់* តថាគតោៗ *សញ្ញីវិសេសយៈ ហើយជា* (និងជា) *លិង្គត្ថៈ,* សុវណ្ណវណ្ណោ *សមាសនាម*

*បទឈ្មោះឆដ្ឋីឧបមាពហុព្វីហិលុត្តសមាសហើយជា* (និងជា) *វិសេសនៈរបស់* តបាគតោ។ *លិង្គត្ថៈ* ។

វិយសព្ទ *ឧបមាជោតកៈក្នុង* វណ្ណោ។ *ឧបមាវិសេសនៈរបស់* វណ្ណោ។ *លិង្គត្ថៈ*, សុវណ្ណស្ស *សាមិសម្ពន្ធក្នុង* វណ្ណោ, អស្ស *វិសេសនៈរបស់* តបាគតស្ស។ *សាមិសម្ពន្ធក្នុង* វណ្ណោ, *ឬថា* វិយសព្ទ *ឧបមាជោតកៈក្នុង* សុវណ្ណស្ស។ *ឧបមាវិសេសនៈរបស់* តបាគតស្ស, អស្ស *វិសេសនៈរបស់* តបាគតស្ស។ *សាមិសម្ពន្ធក្នុង* វណ្ណោ។ *លិង្គត្ថៈ*, ឥតិសព្ទ *ហេតុ*, *ហេត្វត្ថៈ*, *ហេត្វត្ថវាចកៈ*, សោ *វិសេសនៈរបស់* តបាគតោ, សុវណ្ណវណ្ណោ *សញ្ញាវិសេសនៈរបស់* តបាគតោ។ *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ*, សុវណ្ណវណ្ណោ *សមាសនាមបទឈ្មោះឆដ្ឋីឧបមាពហុព្វីហិលុត្តសមាសហើយជា* (និងជា) *វិសេសនៈរបស់* តបាគតោ។ *លិង្គត្ថៈ* ។

📖❋❋

***ឆដ្ឋីកិន្នាធិករណពហុព្វីហិ*** ឧ.

ឯករត្តិំ វាសោ អស្សាតិ = ឯករត្តិវាសោ (ជនោ) ។

សមានេន សំវាសោ អស្សាតិ = សមានសំវាសោ (ជនោ) ។

អសិ ហត្ថេ យស្ស សោ = អសិហត្ថោ (យោធោ) ។

## ប្រែលោតប្រយោគ

វាសោ *វីកិរិយានៅ* ឯករត្តិំ *អស់យប់មួយ* អស្ស ជនស្ស *នៃជននេះ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *វីជននោះ* ឯករត្តិវាសោ *ឈ្មោះ ឯករត្តិវាសោ*, ជនោ *វីជន* ឯករត្តិវាសោ *មានកិរិយានៅអស់យប់មួយ* ។

សំវាសោ *រីកិរិយានៅរួម (មួយអន្លើ)* សមានេន ជនេន *ដោយជនស្មើគ្នា* អស្ស ជនស្ស *នៃជននេះ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *រីជននោះ* សមានសំវាសោ *ឈ្មោះសមានសំវាសោ,* ជនោ *រីជន* សមានសំវាសោ *មានកិរិយានៅរួម (មួយអន្លើ) ដោយជនស្មើគ្នា ។*

អសិ *រីដាវ* ហត្ថេ *ក្នុងដៃ* យស្ស យោធស្ស *នៃទាហានឯណា* សោ យោធោ *រីទាហាននោះ* អសិហត្ថោ *ឈ្មោះអសិហត្ថោ,* យោធោ *រីទាហាន* អសិហត្ថោ *មានដាវក្នុងដៃ ។*

**សម្ពន្ធ**

ឯករត្តិ *អច្ចន្តសំយោគក្នុង* វាសោៗ *លិង្គត្ថៈ,* អស្ស *វិសេសនៈរបស់* ជនស្សៗ *សាមិសម្ពន្ធក្នុង* វាសោ, ឥតិ*សព្ទ ហេតុ (ហេតွត្ថៈ, ហេតွត្ថវាចកៈ),* សោ *វិសេសនៈរបស់* ជនោ, ឯករត្តិវាសោ *សញ្ញាវិសេសនៈរបស់* ជនោៗ *សញ្ញីវិសេសយៈហើយជា (និងជា) លិង្គត្ថៈ,* ឯករត្តិវាសោ *សមាសនាមបទឈ្មោះឆដ្ឋីភិន្នាធិករណពហុព្វីហិលុត្តសមាសហើយជា (និងជា) វិសេសនៈរបស់*ជនោៗ *លិង្គត្ថៈ ។*

សមានេន *វិសេសនៈរបស់* ជនេនៗ *ករណៈក្នុង* សំវាសោៗ *លិង្គត្ថៈ,* អស្ស *វិសេសនៈរបស់* ជនស្សៗ *សាមិសម្ពន្ធក្នុង* សំវាសោ, ឥតិ*សព្ទ ហេតុ (ហេតွត្ថៈ, ហេតွត្ថវាចកៈ)* សោ *វិសេសនៈរបស់* ជនោ, សមានសំវាសោ *សញ្ញាវិសេសនៈរបស់* ជនោៗ *សញ្ញីវិសេសយៈហើយជា (និងជា) លិង្គត្ថៈ,* សមានសំវាសោ *សមាសនាមបទឈ្មោះឆដ្ឋីភិន្នាធិករណពហុព្វីហិលុត្តសមាសហើយជា (និងជា) វិសេសនៈរបស់* ជនោៗ *លិង្គត្ថៈ ។*

យស្ស *វិសេសនៈរបស់* យោធស្សា *សាមិសម្ពន្ធក្នុង* ហត្ថោ *វេសយិកាធារ សត្តមីកិន្នាធិករណៈក្នុង* អសិ *លិង្គត្ថៈ,* សោ *វិសេសនៈរបស់* យោធោ, អសិហត្ថោ *សញ្ញាវិសេសនៈរបស់* យោធោ *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* អសិហត្ថោ *សមាសនាមបទឈ្មោះឆដ្ឋីកិន្នាធិករណពហុព្វីហិ លុត្តសមាសហើយជា* (និងជា) *វិសេសនៈរបស់* យោធោ *លិង្គត្ថៈ។*

📖❊❊

***សហបុព្វបទពហុព្វីហិសមាស*** ឧ. សហ បុត្តេន យោ វត្តតីតិ = សបុត្តោ (បិតា) ។

## ប្រែលោតប្រយោគ

យោ បិតា *រីបិតាឯណា* វត្តតិ *ប្រព្រឹត្តទៅ* សហ *មួយអន្លើ* បុត្តេន *ដោយកូន* ឥតិ *ព្រោះហេតុដូច្នោះ* សោ បិតា *រីបិតានោះ* សបុត្តោ *ឈ្មោះសបុត្តោ,* បិតា *រីបិតា* សបុត្តោ *ប្រព្រឹត្តទៅមួយអន្លើដោយកូន ។*

## សម្ពន្ធ

យោ *វិសេសនៈរបស់* បិតា *សយកត្តាក្នុង* វត្តតិ *អាខ្យាតបទកត្តុវាចកៈ,* បុត្តេន *សហត្ថតតិយាក្នុង* សហ *សព្ទ កិរិយាសមវាយក្នុង* វត្តតិ, ឥតិសព្ទ *ហេតុ* (*ហេត្វត្ថៈ, ហេត្វត្ថវាចកៈ*) សោ *វិសេសនៈរបស់* បិតា, សបុត្តោ *សញ្ញាវិសេសនៈ*

*របស់* បិតា។ *សញ្ញីវិសេសយៈហើយជា* (*និង*ជា) *លិង្គត្ថៈ*, សបុត្តោ *សមាស នាមបទឈ្មោះសហបុព្វបទពហុព្វីហិលុត្តសមាសហើយជា* (*និងជា*) *វិសេសនៈ របស់* បិតា។ *លិង្គត្ថៈ* ។

**វិកប្បសមាស** ឧ. ទ្វីហំ វា តីហំ វា = ទ្វីហតីហំ ។

មតោ វា អមតោ វា = មតាមតោ (ទារកោ) ។

## ប្រែលោតប្រយោគ

ទ្វីហំ វា *រីថ្ងៃពីរឬ* តីហំ វា *ឬថារីថ្ងៃបី* ទ្វីហតីហំ *ឈ្មោះទ្វីហតីហំ*, ទ្វីហតីហំ *រីថ្ងៃពីរឬ។ ថាថ្ងៃបី* ។

យោ ទារកោ *រីក្មេងឯណា* មតោ វា *ស្លាប់ឬ* អមតោ វា *ឬ ថាមិនស្លាប់* សោ ទារកោ *រីក្មេងនោះ* មតាមតោ *ឈ្មោះមតាមតោ*, ទារកោ *រីក្មេង* មតាមតោ *ស្លាប់ឬ។ថាមិនស្លាប់*។

## សម្ពន្ធ

វា *ទាំងពីរសព្ទវិកប្បៈក្នុង* ទ្វីហំ តីហំ, ទ្វីហំក្តី តីហំក្តី *លិង្គត្ថៈ*, ទ្វីហតីហំ *សមាសនាមបទឈ្មោះវិកប្បលុត្តសមាសហើយជា* (*និងជា*) *លិង្គត្ថៈ* ។

យោ *វិសេសនៈរបស់* ទារកោ។ *លិង្គត្ថៈ*, វា *ទាំងពីរសព្ទវិកប្បៈក្នុង*

មតោ អមតោ, មតោក្តី អមតោក្តី *វិសេសនៈរបស់* ទារកោ, សោ *វិសេសនៈរបស់* ទារកោ, មតាមតោ *សមាសនាមបទឈ្មោះវិកប្បលុត្តសមាស ហើយជា* (និងជា) *សញ្ញាវិសេសនៈរបស់ ទារកោៗ សញ្ញីវិសេសយៈហើយជា* (និងជា) *វិសេសនៈរបស់* ទារកោៗ *លិង្គត្ថៈ* ។

📖❋❋

*បុព្វេកសេសៈ* ឧ. ឧបាសកោ ច ឧបាសិកា ច = ឧបាសកា ។

*បរេកសេសៈ* ឧ. ឧបាសកោ ច ឧបាសិកា ច = ឧបាសិកា ។

*សរូបេកសេសៈ* ឧ. បុរិសោ ច បុរិសោ ច = បុរិសា ។

*វិរូបេកសេសៈ* ឧ. មាតា ច បិតា ច = មាតរោ (ឬបិតរោ) ។

សារីបុត្តោ ច មោគ្គល្លានោ ច = សារីបុត្តា (ឬមោគ្គល្លានា) ។

ទស ច ទស ច = វីស (ឬវីសតិ) ។

ទស ច ទស ច ទស ច = តឹស (ឬតឹសតិ) ។

## ប្រែលោតប្រយោគ

*បុព្វេកសេសៈ* ឧបាសកោ ច *រីឧបាសកផង* ឧបាសិកា ច *រីឧបាសិកាផង* ឧបាសកា *ឈ្មោះឧបាសកា*, ឧបាសកា *រីឧបាសកនិងឧបាសិកាទាំងឡាយ* ។

*បរេកសេសៈ* ឧបាសកោ ច *រីឧបាសកផង* ឧបាសិកា ច *រីឧបាសិកាផង*

ឧបាសិកា *ឈ្មោះឧបាសិកា*, ឧបាសិកា *រឺឧបាសកនិងឧបាសិកាទាំងឡាយ ។*

***សរូបេកសេស*:** បុរិសោ ច *រឺបុរសផង* បុរិសោ ច *រឺបុរសផង*, បុរិសា *ឈ្មោះបុរិសា*, បុរិសា *រឺបុរសនិងបុរសទាំងឡាយ ។*

***វិរូបេកសេស*:** មាតា ច *រឺមាតាផង* បិតា ច *រឺបិតាផង* មាតរោ (ឬបិតរោ) *ឈ្មោះមាតរោ (ឬបិតរោ)*, មាតរោ (ឬបិតរោ) *រឺមាតានិងបិតាទាំងឡាយ ។*

សារីបុត្តោ ច *រឺព្រះសារីបុត្តផង* មោគ្គល្លានោ ច *រឺព្រះមោគ្គល្លានផង* សារីបុត្តា (ឬ មោគ្គល្លានា) *ឈ្មោះសារីបុត្តា (ឬមោគ្គល្លានា)* សារីបុត្តា (ឬមោគ្គល្លានា) *រឺព្រះសារីបុត្តនិងព្រះមោគ្គល្លានទាំងឡាយ ។*

ទស ច *ដប់ផង* ទស ច *ដប់ផង* វីស (ឬវីសតិ) *ឈ្មោះ វីស (ឬវីសតិ)* វីស (ឬវីសតិ) *ដប់និងដប់គឺម្ភៃ ។*

ទស ច *ដប់ផង* ទស ច *ដប់ផង* ទស ច *ដប់ផង* តឹស (ឬតឹសតិ) *ឈ្មោះតឹស (ឬតឹសតិ)* តឹស (ឬតឹសតិ) *ដប់និងដប់និងដប់ គឺសាមសិប ។*

## សម្ពន្ធ

***បុព្វេកសេស:*** ច *ទាំងពីរសព្ទបទសមុច្ចយៈក្នុង* ឧបាសកោ ឧបាសិកា ឧបាសកោក្តី ឧបាសិកាក្តី *លិង្គត្ថៈ*, ឧបាសកា *សមាសនាមបទឈ្មោះបុព្វេកសេសលុត្តសមាសហើយជា (និងជា) លិង្គត្ថៈ ។*

***បរេកសេស:*** ច *ទាំងពីរសព្ទបទសមុច្ចយៈក្នុង* ឧបាសកោ ឧបាសិកា

ឧបាសកោក្តី ឧបាសិកាក្តី *លិង្គត្ថ:*, ឧបាសិកា *សមាសនាមបទឈ្មោះ បរេកសេសលុត្តសមាសហើយជា* (និង*ជា*) *លិង្គត្ថ:* ។

***សរូបេកសេស:*** ប *ទាំងពីរសព្ទបទសមុច្ចយ:ក្នុង* បុរិសោ បុរិសោ, បុរិសោក្តី បុរិសោក្តី *លិង្គត្ថ:*, បុរិសា *សមាសនាមបទឈ្មោះសរូបេកសេសលុត្តសមាសហើយជា* (និង*ជា*) *លិង្គត្ថ:* ។

***វិរូបេកសេស:*** ប *ទាំងពីរសព្ទបទសមុច្ចយ:ក្នុង* មាតា បិតា, មាតាក្តី បិតាក្តី *លិង្គត្ថ:*, មាតរោ (ឬបិតរោ) *សមាសនាមបទឈ្មោះ វិរូបេកសេសលុត្តសមាសហើយជា* (និង*ជា*) *លិង្គត្ថ:* ។

ប *ទាំងពីសព្ទបទសមុច្ចយ:ក្នុង*សារីបុត្តោ មោគ្គល្លានោ, សារីបុត្តោក្តី មោគ្គល្លានោក្តី *លិង្គត្ថ:*, សារីបុត្តា (ឬ មោគ្គល្លានា) *សមាសនាមបទឈ្មោះ វិរូបេកសេសលុត្តសមាសហើយជា* (និង*ជា*) *លិង្គត្ថ:* ។

ប *ទាំងពីរសព្ទបទសមុច្ចយ:ក្នុង* ទស ទស, ទសក្តី ទសក្តី *វិសេសន:របស់....*, វីស (ឬវីសតិ) *សមាសនាមបទឈ្មោះវិរូបេកសេសលុត្តសមាសហើយជា* (និង*ជា*) *វិសេសន:របស់.....* ។

ប *ទាំងបីសព្ទបទសមុច្ចយ:ក្នុង* ទស ទស ទស, ទសក្តី ទសក្តី ទសក្តី *វិសេសន:របស់...*, តឹស (ឬតឹសតិ) *សមាសនាមបទឈ្មោះវិរូបេកសេសលុត្តសមាសហើយជា* (និង*ជា*) *វិសេសន:របស់..........* ។

**សមាសផ្ទៃ**

*ឆ.តុ.ព.* ទុ: ទុដ្ឋុំ ពលំ យស្ស សោ = ទុព្វលោ (អស្សោ) ។

*វិ.បុ.កម្ម.* ទុព្វលោ ច សោ អស្សោ ចាតិ = ទុព្វលស្សោ ។

**ប្រែលោតប្រយោគ**

*ឆ.តុ.ព.* ពលំ *វីកម្លាំង* យស្ស អស្សស្ស *នៃសេះណា* ទុ *អាក្រក់ទុគឺថា* ទុដ្ឋុំ ៗ *ខ្សោយ*, សោ អស្សោ *វីសេះនោះ* ទុព្វលោ *ឈ្មោះទុព្វលោ*, អស្សោ *វីសេះ* ទុព្វលោ *មានកម្លាំងខ្សោយ*។

*វិ.បុ.កម្ម.* សោ អស្សោ ច *វីសេះនោះផង* ទុព្វលោ ច *មានកម្លាំងខ្សោយផង* ឥតិ *ព្រោះហេតុដូច្នោះ* ទុព្វលស្សោ *ឈ្មោះទុព្វលស្សោ*, ទុព្វលស្សោ *វីសេះមានកម្លាំងខ្សោយ* ។

**សម្ពន្ធ**

យស្ស *វិសេសនៈរបស់* អស្សស្សៗ *សាមិសម្ពន្ធក្នុង* ពលំ ៗ *លិង្គត្ថៈ*, ទុ *បទវិវរណៈក្នុង* ទុដ្ឋុំ ៗ *បទវិវរណីយៈហើយជា* (និងជា) *វិសេសនៈរបស់* ពលំ, សោ *វិសេសនៈរបស់* អស្សោ, ទុព្វលោ *សញ្ញាវិសេសនៈរបស់*អស្សោៗ *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ*, ទុព្វលោ *សមាសនាមបទឈ្មោះឆដ្ឋីតុល្យាធិករណពហុព្វីហិលុត្តសមាសហើយជា* (និងជា) *វិសេសនៈរបស់* អស្សោ ៗ *លិង្គត្ថៈ* ។

ច *ទាំងពីរសព្ទបទបូរណៈក្នុង* ទុព្វលោ អស្សោ, ទុព្វលោក្តី សោក្តី *វិសេសនៈរបស់* អស្សោៗ *លិង្គត្ថៈ*, ឥតិសព្ទ *ហេតុ* (*ហេត្វត្ថៈ*, *ហេត្វត្ថវាចកៈ*) ទុព្វលស្សោ *សមាសនាមបទឈ្មោះវិសេសនៈបុព្វបទកម្មធារយលុត្តសមាស* មានឆដ្ឋីតុល្យា *ធិករណពហុព្វីហិលុត្តសមាសជាផ្ទៃ ហើយជា* (និងជា) *លិង្គត្ថៈ*) ។

បែបប្រែលោតប្រយោគ និងសម្ពន្ធក្នុងវិគ្គហៈនៃសមាសចប់តែប៉ុណ្ណោះ ។

## ប្រែលោតប្រយោគ និងសម្ពន្ធ

## ក្នុងវិគ្គហៈនៃតទ្ធិត

***គោត្តតទ្ធិត*** ឬ***អបច្ចតទ្ធិត*** ឧ. វសិដ្ឋស្ស អបច្ចំ = វាសិដ្ឋោ (ជនោ) ។

### ប្រែលោតប្រយោគ

យោ ជនោ *រីជនឯណា* អបច្ចំ *ជាកូន* (*ជាពូជពង្ស ជាកូនចៅ*) វសិដ្ឋស្ស *នៃវសិដ្ឋៈ* សោ ជនោ *រីជននោះ* វាសិដ្ឋោ *ឈ្មោះវាសិដ្ឋោ* ជនោ *រីជន* វាសិដ្ឋោ *ជាកូននៃវសិដ្ឋៈ* (*ជាពូជពង្សនៃវសិដ្ឋៈ*) ។

### សម្ពន្ធ

យោ *វិសេសនៈរបស់* ជនោ ៗ *លិង្គត្ថៈ*, វសិដ្ឋស្ស *សាមិសម្ពន្ធក្នុង* អបច្ចំ ៗ *នានាលិង្គត្ថវិសេសនៈរបស់* ជនោ, សោ *វិសេសនៈរបស់* ជនោ, វាសិដ្ឋោ *សញ្ញាវិសេសនៈរបស់* ជនោ ៗ *សញ្ញីវិសេសយៈ ហើយជា*(*និងជា*) *លិង្គត្ថៈ*, វាសិដ្ឋោ *តទ្ធិតនាមបទឈ្មោះគោត្តតទ្ធិត ឬ អបច្ចតទ្ធិត ហើយជា* (*និងជា*) *វិសេសនៈរបស់* ជនោ ៗ *លិង្គត្ថៈ* ។

ឯឧទាហរណ៍នៃគោត្តតទ្ធិតក្រៅពីនេះ ប្រែលោតប្រយោគនិងសម្ពន្ធដូចគ្នានឹងវាសិដ្ឋោនេះដែរ ប្លែកគ្នាតែរូបសព្ទនិងបច្ច័យប៉ុណ្ណោះ ។

***តរតិតទ្ធិត*** ឧ. នាវាយ តរតីតិ = នាវិកោ (ជនោ) ។

### ប្រែលោតប្រយោគ

យោ ជនោ *រីជនណា* តរតិ *ឆ្លង* នទឹ *នូវទន្លេ* នាវាយ *ដោយ*

*ទូក* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *រីជននោះ* នាវិកោ *ឈ្មោះនាវិកោ*

ជនោ *រីជន* នាវិកោ *ធ្វង (ទូវទន្ទ្វេ) ដោយទូក ។*

**សម្ពន្ធ**

យោ *វិសេសនៈរបស់ជនោ ៗ សយកត្តាក្នុងតរតិ ៗ អាខ្យាតបទកត្តុវាចកៈ*

នាវាយ *ករណៈក្នុងតរតិ,* ឥទំ *អវុត្តកម្មក្នុង* តរតិ, ឥតិសព្ទ *ហេតុ, ហេត្វត្ថវាចកៈ,*

សោ *វិសេសនៈរបស់ជនោ,* នាវិកោ *សញ្ញាវិសេសនៈរបស់ជនោ ៗ*

*សញ្ញីវិសេសយៈ ហើយជា (និងជា) លិង្គត្ថៈ,* នាវិកោ *តទ្ធិតនាមបទឈ្មោះ*

*តរតិតទ្ធិត (ឬ តរតទ្ធិត) ហើយជា (និងជា) វិសេសនៈរបស់ជនោ ៗ*

*លិង្គត្ថៈ ។*

***សំសដ្ឋតទ្ធិត*** ឧ. តិលេន សំសដ្ឋំ (ភោជនំ) = តេលិកំ ។

**ប្រែលោតប្រយោគ**

យំ ភោជនំ *រីភោជនឯណា* សំសដ្ឋំ *ដែលជនលាយហើយ* តិលេន

*ដោយល្ង* តំ ភោជនំ *រីភោជននោះ* តេលិកំ *ឈ្មោះតេលិកំ* ភោជនំ *រីភោជន*

តេលិកំ *ដែលជនលាយហើយដោយល្ង ។*

**សម្ពន្ធ**

យំ *វិសេសនៈរបស់ភោជនំ ៗ លិង្គត្ថៈ,* តិលេន *ករណៈក្នុងសំសដ្ឋំ ៗ*

*វិសេសនៈរបស់ភោជនំ,* តំ *វិសេសនៈរបស់ភោជនំ,* តេលិកំ *សញ្ញាវិសេសនៈ*

*របស់ភោជនំ ។ សញ្ញីវិសេសយៈហើយជា*(និង*ជា*) *លិង្គត្ថៈ*, តេលិកំ *តទ្ធិតនាមបទឈ្មោះសំសដ្ឋតទ្ធិត ហើយជា* (និង*ជា*) *វិសេសនៈរបស់ភោជនំ* ។ *លិង្គត្ថៈ* ។

***ចរតិតទ្ធិត*** ឧ. សកដេន ចរតីតិ = សាកដិកោ (ជនោ) ។

### ប្រែលោតប្រយោគ

យោ ជនោ *រីជនឯណា* ចរតិ *ដើរ* សកដេន *ដោយរទេះ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *រីជននោះ* សាកដិកោ *ឈ្មោះសាកដិកោ* ជនោ *រីជន* សាកដិកោ *ដើរដោយរទេះ* ។

### សម្ពន្ធ

យោ *វិសេសនៈរបស់ជនោ ។ សយកត្តាក្នុងចរតិ ។ អាខ្យាតបទកត្តុវាចកៈ* សកដេន *ករណៈក្នុងចរតិ*, ឥតិសព្ទ *ហេតុ* (*ហេតុត្ថៈ*, *ហេតុត្ថវាចកៈ*) សោ *វិសេសនៈរបស់ជនោ*, សាកដិកោ *សញ្ញាវិសេសនៈរបស់ជនោ ។ សញ្ញីវិសេសយៈ ហើយជា* (និង*ជា*) *លិង្គត្ថៈ*, សាកដិកោ *តទ្ធិតនាមបទឈ្មោះចរតិតទ្ធិត* (*ឬ ចរតទ្ធិត*) *ហើយជាវិសេសនៈរបស់ជនោ ។ លិង្គត្ថៈ* ។

***វហតិតទ្ធិត*** ឧ. សីសេន វហតីតិ = សីសិកោ (ជនោ) ។

### ប្រែលោតប្រយោគ

យោ ជនោ *រីជនណា* វហតិ *នាំទៅ* (*កុម្ពុំ នូវក្អម*) សីសេន

*ដោយក្បាល* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *ជននោះ* សីសិកោ *ឈ្មោះសីសិកោ* ជនោ *ជន* សីសិកោ *នាំទៅ (នូវក្អម) ដោយក្បាល (អ្នកទូល)* ។

**សម្ពន្ធ**

យោ *វិសេសនៈរបស់*ជនោ ៗ *សយកត្តាក្នុង*វហតិ ៗ *អាខ្យាតបទកត្តុវាចកៈ* សីសេន *ករណៈក្នុង*វហតិ, កុម្ភំ *អវុត្តកម្មក្នុង*វហតិ, ឥតិសព្ទ *ហេតុ (ហេតុត្ថៈ, ហេតុត្ថវាចកៈ)*, សោ *វិសេសនៈរបស់*ជនោ, សីសិកោ *សញ្ញាវិសេសនៈរបស់*ជនោ ៗ *សញ្ញីវិសេសយៈហើយជា(និងជា) លិង្គត្ថៈ*, សីសិកោ *តទ្ធិតនាមបទឈ្មោះវហតិតទ្ធិត (ឬវហតទ្ធិត) ហើយជា (និងជា) វិសេសនៈរបស់*ជនោ ៗ *លិង្គត្ថៈ* ។

***វសតិតទ្ធិត*** ឧ. មគធេ វសតីតិ = មាគធិកោ (ជនោ) ។

**ប្រែលោតប្រយោគ**

យោ ជនោ *ជនឯណា* វសតិ *នៅ* មគធេ *ក្នុងដែនមគធៈ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *ជននោះ* មាគធិកោ *ឈ្មោះមាគធិកោ* ជនោ *ជន* មាគធិកោ *នៅក្នុងដែនមគធៈ* ។

**សម្ពន្ធ**

យោ *វិសេសនៈរបស់*ជនោ ៗ *សយកត្តាក្នុង*វសតិ ៗ *អាខ្យាតបទកត្តុវាចកៈ*, មគធេ *វេសយិកាធារៈក្នុង*វសតិ, ឥតិសព្ទ *ហេតុ (ហេតុត្ថៈ, ហេតុត្ថវាចកៈ)*, សោ *វិសេសនៈរបស់* ជនោ, មាគធិកោ *សញ្ញាវិសេសនៈរបស់* ជនោ ៗ *សញ្ញីវិសេសយៈ*

*ហើយជា* (*និងជា*) *លិង្គត្ថៈ* មាគធិកោ *តទ្ធិតនាមបទឈ្មោះវសតិតទ្ធិត* (*ឬ វសតទ្ធិត*) *ហើយជា* (*និងជា*) *វិសេសនៈរបស់*ជនោ ។ *លិង្គត្ថៈ*។

***ជាតតទ្ធិត*** ឧ. ឥន្ទបត្តេ ជាតោ = ឥន្ទបត្តិកោ (ជនោ) ។

## ប្រែលោតប្រយោគ

យោ ជនោ *រីជនឯណា* ជាតោ *កើតហើយ* ឥន្ទបត្តេ *ក្នុងនគរឥន្ទបត្ត* សោ ជនោ *រីជននោះ* ឥន្ទបត្តិកោ *ឈ្មោះឥន្ទបត្តិកោ* ជនោ *រីជន* ឥន្ទបត្តិកោ *កើតហើយក្នុងនគរឥន្ទបត្ត* ។

## សម្ពន្ធ

យោ *វិសេសនៈរបស់*ជនោ ។ *លិង្គត្ថៈ*, ឥន្ទបត្តេ *វិសយិកាធារៈក្នុង*ជាតោ ។ *វិសេសនៈរបស់*ជនោ, សោ *វិសេសនៈរបស់*ជនោ, ឥន្ទបត្តិកោ *សញ្ញាវិសេសនៈរបស់*ជនោ ។ *សញ្ញីវិសេសយៈ ហើយជា* (*និងជា*) *លិង្គត្ថៈ*, ឥន្ទបត្តិកោ *តទ្ធិតនាមបទឈ្មោះជាតតទ្ធិត ហើយជា* (*និងជា*) *វិសេសនៈរបស់*ជនោ ។ *លិង្គត្ថៈ* ។

***អធីតេតទ្ធិត*** ឧ. វិនយំ អធីតេតិ = វេនយិកោ (ភិក្ខុ) ។

## ប្រែលោតប្រយោគ

យោ ភិក្ខុ *រីភិក្ខុឯណា* អធីតេ *រៀន* វិនយំ *នូវវិន័យ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ភិក្ខុ *រីភិក្ខុនោះ* វេនយិកោ *ឈ្មោះវេនយិកោ* ភិក្ខុ *រីភិក្ខុ* វេនយិកោ *រៀននូវវិន័យ* (*អ្នករៀនវិន័យ អ្នកចេះវិន័យ*) ។

**សម្ពន្ធ**

យោ *វិសេសនៈរបស់ភិក្ខុ ។ សយកត្តាក្នុងអធីតេ ។ អាខ្យាតបទកត្តុវាចកៈ*, វិធយំ *អវុត្តកម្មក្នុងអធីតេ*, ឥតិសព្ទ *ហេតុ* (*ហេតុត្ថៈ*, *ហេតុត្ថវាចកៈ*), សោ *វិសេសនៈរបស់ភិក្ខុ*, វេធយិកោ *សញ្ញាវិសេសនៈរបស់ភិក្ខុ ។ សញ្ញីវិសេសយៈ ហើយជា* (*និងជា*) *លិង្គត្ថៈ*, វេធយិកោ *តទ្ធិតនាមបទឈ្មោះអធីតេតទ្ធិត ហើយជា*(*និងជា*) *វិសេសនៈរបស់ភិក្ខុ ។ លិង្គត្ថៈ ។*

📖❋❋

***កតតទ្ធិត*** ឧ. កាយេន កតំ (កម្មំ) = កាយិកំ ។

**ប្រែលោតប្រយោគ**

យំ កម្មំ *វីអំពើឯណា* កតំ *ដែលបុគ្គលធ្វើហើយ* កាយេន *ដោយកាយ* តំ កម្មំ *វីអំពើនោះ* កាយិកំ *ឈ្មោះកាយិកំ* កម្មំ *វីអំពើ* កាយិកំ *ដែលបុគ្គលធ្វើហើយដោយកាយ ។*

**សម្ពន្ធ**

យំ *វិសេសនៈរបស់កម្មំ ។ លិង្គត្ថៈ*, កាយេន *ករណៈក្នុងកតំ។ វិសេសនៈរបស់កម្មំ*, តំ *វិសេសនៈរបស់កម្មំ*, កាយិកំ *សញ្ញាវិសេសនៈរបស់កម្មំ។ សញ្ញីវិសេសយៈហើយជា* (*និងជា*) *លិង្គត្ថៈ*, កាយិកំ *តទ្ធិតនាមបទឈ្មោះកតតទ្ធិត ហើយជា* (*និងជា*) *វិសេសនៈរបស់កម្មំ។ លិង្គត្ថៈ ។*

📖❋❋

***វត្តិតទ្ធិត*** ឧ. កាយេ វត្តតីតិ = កាយិកំ (កម្មំ) ។

## ប្រែលោតប្រយោគ

យំ កម្មំ *រីកម្មឯណា* វត្តតិ *ប្រព្រឹត្តទៅ* កាយេ *ក្នុងកាយ* ឥតិ *ព្រោះហេតុដូច្នោះ* តំ កម្មំ *រីកម្មនោះ* កាយិកំ *ឈ្មោះកាយិកំ* កម្មំ *រីកម្ម* កាយិកំ *ប្រព្រឹត្តទៅក្នុងកាយ ។*

## សម្ពន្ធ

យំ *វិសេសនៈរបស់កម្មំៗ សយកត្តាក្នុងវត្តតិៗ អាខ្យាតបទកត្តុវាចកៈ,* កាយេ *វេសយិកាធារៈក្នុងវត្តតិ,* ឥតិ *សព្ទហេតុ (ហេតូត្ថៈ, ហេតូត្ថវាចកៈ),* តំ *វិសេសនៈរបស់កម្មំ,* កាយិកំ *សញ្ញាវិសេសនៈរបស់កម្មំៗ សញ្ញីវិសេសយៈ ហើយជា* (និងជា) *លិង្គត្ថៈ,* កាយិកំ *តទ្ធិតនាមបទឈ្មោះវត្តតិតទ្ធិត ឬ វត្តតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់កម្មំៗ លិង្គត្ថៈ ។*

***សន្និធានតទ្ធិត*** ឧ. សរីរេ សន្និធាតា (វេទនា) = សារីរិកា ។

## ប្រែលោតប្រយោគ

យា វេទនា *រីវេទនាឯណា* សន្និធាតា *អាស្រ័យនៅ* សរីរេ *ក្នុងសរីរៈ* សា វេទនា *រីវេទនានោះ* សារីរិកា *ឈ្មោះសារីរិកា* វេទនា *រីវេទនា* សារីរិកា *អាស្រ័យនៅក្នុងសរីរៈ ។*

## សម្ពន្ធ

យា *វិសេសនៈរបស់វេទនាៗ លិង្គត្ថៈ,* សរីរេ *វេសយិកាធារៈក្នុងសន្និធាតា* ។ *វិសេសនៈរបស់* វេទនា, សា *វិសេសនៈរបស់* វេទនា, សារីរិកា *សញ្ញាវិសេសនៈ*

*របស់វេទនា ។ សញ្ញីវិសេសយៈ ហើយជា* (និងជា) *លិង្គត្ថៈ,* សារីរិកា *តទ្ធិតនាមបទឈ្មោះសន្និធានតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់វេទនាៗ លិង្គត្ថៈ ។*

📖❀❀

***និយុត្តតទ្ធិត*** ឧ. ទ្វារេ និយុត្តោ = ទោវារិកោ (ជនោ) ។

**ប្រែលោតប្រយោគ**

យោ ជនោ *វីជនឯណា* និយុត្តោ *ប្រកប* ទ្វារេ *ក្នុងទ្វារ* សោ ជនោ *វីជននោះ* ទោវារិកោ *ឈ្មោះទោវារិកោ* ជនោ *វីជន* ទោវារិកោ *ប្រកបក្នុងទ្វារ ។*

**សម្ពន្ធ**

យោ *វិសេសនៈរបស់* ជនោៗ *លិង្គត្ថៈ* ទ្វារេ *វេសយិកាធារៈក្នុងនិយុត្តោៗ វិសេសនៈរបស់ជនោ,* សោ *វិសេសនៈរបស់ជនោ,* ទោវារិកោ *សញ្ញាវិសេសនៈ របស់ជនោៗ សញ្ញីវិសេសយៈហើយជា* (និងជា) *វិសេសនៈរបស់ជនោៗ លិង្គត្ថៈ ។*

📖❀❀

***សិប្បតទ្ធិត*** ឧ. វីណា អស្ស សិប្បន្តិ = វេណិកោ (ជនោ) ។

**ប្រែលោតប្រយោគ**

វីណា *វីកិរិយាដេញនូវពិណ* សិប្បំ *ជាសិល្បៈ* អស្ស *ជនស្ស នៃជននេះ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *វីជននោះ* វេណិកោ *ឈ្មោះវេណិកោ* ជនោ *វីជន* វេណិកោ *មានកិរិយាដេញនូវពិណជាសិល្បៈ ។*

## សម្ពន្ធ

អស្ស *វិសេសនៈរបស់ធនស្សំ* *សាមិសម្ពន្ធៈក្នុងសិប្បំ* នានាលិង្គត្ថ *វិសេសនៈរបស់វីណាំ* *លិង្គត្ថៈ*, ឥតិសទ្ទ *ហេតុ* (*ហេតុត្ថៈ*, *ហេតុត្ថវាចកៈ*) សោ *វិសេសនៈរបស់ធនោ*, វេណិកោ *សញ្ញាវិសេសនៈរបស់ធនោ* *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ*, វេណិកោ *តទ្ធិតនាមបទឈ្មោះសិប្បតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់ធនោ* *លិង្គត្ថៈ* ។

📖❋❋

***ភណ្ឌតទ្ធិត*** ឱ. គន្ធោ អស្ស ភណ្ឌំ = គន្ធិកោ (ធនោ) ។

## ប្រែលោតប្រយោគ

គន្ធោ *វីគ្រឿងក្រអូប* ភណ្ឌំ *ជាទ្រព្យ* អស្ស ធនស្ស *នៃជននេះ* សោ ធនោ *វីជននោះ* គន្ធិកោ *ឈ្មោះគន្ធិកោ* ធនោ *វីជន* គន្ធិកោ *មានគ្រឿងក្រអូបជាទ្រព្យ* ។

## សម្ពន្ធ

អស្ស *វិសេសនៈរបស់ធនស្សំ* *សាមិសម្ពន្ធក្នុងភណ្ឌំ* នានាលិង្គត្ថ *វិសេសនៈរបស់គន្ធោ* *លិង្គត្ថៈ* សោ *វិសេសនៈរបស់* ធនោ, គន្ធិកោ *សញ្ញាវិសេសនៈរបស់ធនោ* *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ*, គន្ធិកោ *តទ្ធិតនាមបទឈ្មោះភណ្ឌតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់ធនោ* *លិង្គត្ថៈ* ។

📖❋❋

***ជីវតិតទ្ធិត*** ឧ. ឱរព្ភំ ហន្ត្វា ជីវតីតិ = ឱរព្ភិកោ (ជនោ) ។

**ប្រែលោតប្រយោគ**

យោ ជនោ *រីជនឯណា* ហន្ត្វា *សម្លាប់ហើយ* ឱរព្ភំ *នូវចៀម* ជីវតិ *ចិញ្ចឹមជីវិត* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *រីជននោះ* ឱរព្ភិកោ *ឈ្មោះឱរព្ភិកោ* ជនោ *រីជន* ឱរព្ភិកោ *សម្លាប់នូវចៀមហើយចិញ្ចឹមជីវិត ។*

**សម្ពន្ធ**

យោ *វិសេសនៈរបស់ជនោៗ សយកត្តាក្នុងជីវតិៗ អាខ្យាតបទកត្តុវាចកៈ* ឱរព្ភំ *អវុត្តកម្មក្នុងហន្ត្វាៗ បុព្វកាលកិរិយាក្នុងជីវតិ*, ឥតិសព្ទ *ហេតុត្ថវាចកៈ*, សោ *វិសេសនៈរបស់ជនោ*, ឱរព្ភិកោ *សញ្ញាវិសេសនៈរបស់ជនោៗ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ*, ឱរព្ភិកោ *តទ្ធិតនាមបទឈ្មោះជីវតិតទ្ធិត ឬឈ្មោះហន្ត្វាជីវតិតទ្ធិត, ហើយជា* (និងជា) *វិសេសនៈរបស់ជនោៗ លិង្គត្ថៈ ។*

📖❋❋

***ហតតទ្ធិត*** ឧ. ជាលេន ហតោ = ជាលិកោ (សត្តោ) ។

**ប្រែលោតប្រយោគ**

យោ សត្តោ *រីសត្វឯណា* ហតោ *ដែលជនសម្លាប់ហើយ* ជាលេន *ដោយសំណាញ់* សោ សត្តោ *រីសត្វនោះ* ជាលិកោ *ឈ្មោះជាលិកោ* សត្តោ *រីសត្វ* ជាលិកោ *ដែលជនសម្លាប់ហើយដោយសំណាញ់ ។*

**សម្ពន្ធ**

យោ *វិសេសនៈរបស់សត្តោ ៗ លិង្គត្ថៈ,* ជាលេន *ករណៈក្នុងហតោ ៗ វិសេសនៈរបស់សត្តោ,* សោ *វិសេសនៈរបស់សត្តោ,* ជាលិកោ *សញ្ញាវិសេសនៈ របស់សត្តោ ៗ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* ជាលិកោ *តទ្ធិតនាមបទឈ្មោះហាតតទ្ធិត ហើយជា* (និងជា) *វិសេសនៈរបស់សត្តោ ៗ លិង្គត្ថៈ ។*

📖❋❋

***ពន្ធតទ្ធិត*** ឧ. សុត្តេន ពន្ធោ = សុត្តិកោ (សត្តោ) ។

**ប្រែលោតប្រយោគ**

យោ សត្តោ *វិសត្តឯណា* ពន្ធោ *ដែលជនចងហើយ* សុត្តេន *ដោយ ចេស* សោ សត្តោ *វីសត្វនោះ* សុត្តិកោ *ឈ្មោះសុត្តិកោ* សត្តោ *វីសត្វ* សុត្តិកោ *ដែលជនចងដោយចេស ។*

**សម្ពន្ធ**

យោ *វិសេសនៈរបស់សត្តោ ៗ លិង្គត្ថៈ,* សុត្តេន *ករណៈក្នុងពន្ធោ ៗ វិសេសនៈរបស់* សត្តោ, សោ *វិសេសនៈរបស់សត្តោ* សុត្តិកោ *សញ្ញាវិសេសនៈ*

*របស់សត្ថោ។ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* សុត្តិកោ *តទ្ធិតនាមបទឈ្មោះពន្ធតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់សត្ថោ។ លិង្គត្ថៈ ។*

📖❋❋

***អាវុធតទ្ធិត*** ឧ. មុសលោ អស្ស អាវុធោ = មោសលិកោ (ជនោ) ។

**ប្រែលោតប្រយោគ**

មុសលោ *រីអង្រែ* អាវុធោ *ជាអាវុធ* អស្ស ជនស្ស *នៃជននេះ* សោ ជនោ *រីជននោះ* មោសលិកោ *ឈ្មោះមោសលិកោ* ជនោ *រីជន* មោសលិកោ *មានអង្រែជាអាវុធ ។*

**សម្ពន្ធ**

អស្ស *វិសេសនៈរបស់ជនស្ស។ សាមិសម្ពន្ធក្នុង*អាវុធោ។ *វិសេសនៈរបស់*មុសលោ។ *លិង្គត្ថៈ,* សោ *វិសេសនៈរបស់*ជនោ, មោសលិកោ *សញ្ញាវិសេសនៈរបស់*ជនោ។ *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* មោសលិកោ *តទ្ធិតនាមបទឈ្មោះអាវុធតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់*ជនោ ។ *លិង្គត្ថៈ ។*

📖❋❋

***អាពាធតទ្ធិត*** ឧ. វាតោ អស្ស អាពាធោ = វាតិកោ (ជនោ) ។

**ប្រែលោតប្រយោគ**

វាតោ *វិខ្យល់* អាពាធោ *ជាអាពាធ* អស្ស ជនស្ស *នៃជននេះ* សោ ជនោ *វីជននោះ* វាតិកោ *ឈ្មោះវាតិកោ* ជនោ *វីជន* វាតិកោ *មានខ្យល់ជាអាពាធ ។*

**សម្ពន្ធ**

អស្ស *វិសេសនៈរបស់ជនស្ស ។ សាមិសម្ពន្ធក្នុងអាពាធោ។ វិសេសនៈរបស់វាតោ។ លិង្គត្ថៈ,* សោ *វិសេសនៈរបស់ជនោ,* វាតិកោ *សញ្ញាវិសេសនៈរបស់ជនោ។ សញ្ញីវិសេសយៈហើយជា* (*និងជា*) *លិង្គត្ថៈ,* វាតិកោ *តទ្ធិតនាមបទឈ្មោះអាពាធតទ្ធិតហើយជា* (*និងជា*) *វិសេសនៈរបស់ជនោ។ លិង្គត្ថៈ ។*

📖❋❋

***បសន្នតទ្ធិត*** ឧ. ពុទ្ធេ បសន្នោ = ពុទ្ធិកោ (ជនោ) ។

**ប្រែលោតប្រយោគ**

យោ ជនោ *វីជនឯណា* បសន្នោ *ជ្រះថ្លាហើយ* ពុទ្ធេ *ក្នុងព្រះពុទ្ធ* សោ ជនោ *វីជននោះ* ពុទ្ធិកោ *ឈ្មោះពុទ្ធិកោ* ជនោ *វីជន* ពុទ្ធិកោ *ជ្រះថ្លាហើយក្នុងព្រះពុទ្ធ ។*

## សម្ពន្ធ

យោ វិសេសនៈរបស់ធិតោៗ លិង្គត្ថៈ, ពុទ្ធេ វេសយិកាធារៈក្នុងបសន្នោៗ វិសេសនៈរបស់ធិតោ, សោ វិសេសនៈរបស់ធិតោ, ពុទ្ធិកោ សញ្ញាវិសេសនៈរបស់ធិតោៗ សញ្ញីវិសេសយៈហើយជា (និងជា) លិង្គត្ថៈ, ពុទ្ធិកោ តទ្ធិតនាមបទឈ្មោះបសន្នតទ្ធិតហើយជា (និងជា) វិសេសនៈរបស់ធិតោៗ លិង្គត្ថៈ ។

**សន្តកតទ្ធិត** ឧ. សង្ឃស្ស សន្តកំ = សង្ឃិកំ (ភណ្ឌំ) ។

## ប្រែលោតប្រយោគ

យំ ភណ្ឌំ រីភណ្ឌៈឯណា សន្តកំ ជារបស់ សង្ឃស្ស នៃសង្ឃ តំ ភណ្ឌំ រីភណ្ឌៈនោះ សង្ឃិកំ ឈ្មោះសង្ឃិកំ ភណ្ឌំ រីភណ្ឌៈ សង្ឃិកំ ជារបស់នៃសង្ឃ ។

## សម្ពន្ធ

យំ វិសេសនៈរបស់ភណ្ឌំៗ លិង្គត្ថៈ, សង្ឃស្ស សាមិសម្ពន្ធក្នុងសន្តកំៗ វិសេសនៈរបស់ភណ្ឌំ, តំ វិសេសនៈរបស់ភណ្ឌំ, សង្ឃិកំ សញ្ញាវិសេសនៈរបស់ភណ្ឌំៗ សញ្ញីវិសេសយៈហើយជា (និងជា) លិង្គត្ថៈ, សង្ឃិកំ តទ្ធិតនាមបទឈ្មោះសន្តកតទ្ធិតហើយជា (និងជា) វិសេសនៈរបស់ភណ្ឌំៗ លិង្គត្ថៈ ។

***កីតតទ្ធិត*** ឧ. សុវណ្ណេន កីតំ (ភណ្ឌំ) = សោវណ្ណិកំ ។

## ប្រែលោតប្រយោគ

យំ ភណ្ឌំ *រីភណ្ឌៈឯណា* កីតំ *ដែលជនទិញហើយ* សុវណ្ណេន *ដោយមាស* តំ ភណ្ឌំ *រីភណ្ឌៈនោះ* សោវណ្ណិកំ *ឈ្មោះសោវណ្ណិកំ* ភណ្ឌំ *រីភណ្ឌៈ* សោវណ្ណិកំ *ដែលជនទិញហើយដោយមាស ។*

## សម្ពន្ធ

យំ *វិសេសនៈរបស់ភណ្ឌំៗ លិង្គត្ថៈ*, សុវណ្ណេន *ករណៈក្នុងកីតំៗ វិសេសនៈរបស់ភណ្ឌំ*, តំ *វិសេសនៈរបស់ភណ្ឌំ*, សោវណ្ណិកំ *សញ្ញាវិសេសនៈរបស់ភណ្ឌំៗ សញ្ញីវិសេសយៈហើយជា* (និង៍ជា) *លិង្គត្ថៈ*, សោវណ្ណិកំ *តទ្ធិតនាមបទឈ្មោះកីតតទ្ធិតហើយជា* (និង៍ជា) *វិសេសនៈរបស់ភណ្ឌំៗ លិង្គត្ថៈ។*

📖❋❋

***បរិមាណតទ្ធិត*** ឧ. កុម្ភោ អស្ស បរិមាណំ = កុម្ភិកំ (វត្ថុ) ។

## ប្រែលោតប្រយោគ

កុម្ភោ *រីថ្នាំង* បរិមាណំ *ជាប្រមាណ* អស្ស វត្ថុនោ *នៃវត្ថុនេះ* តំ វត្ថុ *រីវត្ថុនោះ* កុម្ភិកំ *ឈ្មោះកុម្ភិកំ* វត្ថុ *រីវត្ថុ* កុម្ភិកំ *មានថ្នាំងជាប្រមាណ (ប្រមាណមួយថ្នាំង ឬប្រមាណប៉ុនថ្នាំង)* ។

**សម្ពន្ធ**

អស្ស *វិសេសនៈរបស់វត្ថុនោៗ សាមិសម្ពន្ធក្នុងបរិមាណំៗ* នានាលិង្គត្ថៈ *វិសេសនៈរបស់កុម្ភោៗ លិង្គត្ថៈ*, ធំ *វិសេសនៈរបស់វត្ថុ*, កុម្ភិកំ *សញ្ញាវិសេសនៈរបស់វត្ថុៗ សញ្ញីវិសេសយៈហើយជា* (*និងជា*) *លិង្គត្ថៈ*, កុម្ភិកំ *តទ្ធិតនាមបទឈ្មោះបរិមាណតទ្ធិតហើយជា* (*និងជា*) *វិសេសនៈរបស់វត្ថុៗ លិង្គត្ថៈ* ។

📖⊠⊠

***រាសិតទ្ធិត*** ឧ. កុម្ភានំ រាសិ = កុម្ភិកោ ។

**ប្រែលោតប្រយោគ**

រាសិ *វីគំនរ* កុម្ភានំ *នៃឆ្នាំងទាំងឡាយ* កុម្ភិកោ *ឈ្មោះកុម្ភិកោ* កុម្ភិកោ *វីគំនរនៃឆ្នាំង* ។

**សម្ពន្ធ**

កុម្ភានំ *សម្ពហសម្ពន្ធៈក្នុងរាសិៗ លិង្គត្ថៈ*, កុម្ភិកោ *តទ្ធិតនាមបទឈ្មោះរាសិតទ្ធិតហើយជា* (*និងជា*) *លិង្គត្ថៈ* ។

📖⊠⊠

***អរហតិតទ្ធិត*** ឧ. កុម្ភំ អរហតីតិ = កុម្ភិកោ (ជនោ) ។

## ប្រែលោតប្រយោគ

យោ ជនោ *ជនឯណា* អរហតិ *គួរ* (នេតុំ *ដើម្បីនាំទៅ*) កុម្ភំ *នូវទ្រព្យមួយកុម្ភៈ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *ជននោះ* កុម្ភិកោ *ឈ្មោះកុម្ភិកោ*, ជនោ *ជន* កុម្ភិកោ *គួរដើម្បីនាំទៅនូវទ្រព្យមួយកុម្ភៈ* ។

## សម្ពន្ធ

យោ *វិសេសនៈរបស់ជនោៗ សយកត្តាក្នុងអរហតិៗ អាខ្យាតបទកត្តុវាចកៈ*, កុម្ភំ *អវុត្តកម្មក្នុងនេតុំៗ តុមត្ថសម្បទានក្នុងអរហតិ*, ឥតិសព្ទ *ហេត្វត្ថវាចកៈ*, សោ *វិសេសនៈរបស់ជនោ*, កុម្ភិកោ *សញ្ញាវិសេសនៈរបស់ជនោៗ សញ្ញី វិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ*, កុម្ភិកោ *តទ្ធិតនាមបទឈ្មោះអរហតិតទ្ធិត ហើយជា* (និងជា) *វិសេសនៈរបស់ជនោៗ លិង្គត្ថៈ* ។

***ទិព្វតិតទ្ធិត*** ឧ. អក្ខេន ទិព្វតីតិ = អក្ខិកោ (ជនោ) ។

## ប្រែលោតប្រយោគ

យោ ជនោ *ជនឯណា* ទិព្វតិ *លេង* អក្ខេន *ដោយខ្លាច់* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *ជននោះ* អក្ខិកោ *ឈ្មោះអក្ខិកោ* ជនោ *ជន* អក្ខិកោ *លេងដោយខ្លាច់* (*ឬលេងដោយស្កា*) ។

**សម្ពន្ធ**

យោ *វិសេសនៈរបស់ធិតោ។* *សយកត្តាក្នុងទិព្វតិ។* *អាខ្យាតបទកត្តុវាចកៈ,* អក្ខេន *ករណៈក្នុងទិព្វតិ,* ផតិសព្ទ *ហេតុត្ថវាចកៈ,* សោ *វិសេសនៈរបស់ធិតោ,* អក្ខិកោ *សញ្ញាវិសេសនៈរបស់ធិតោ។* *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* អក្ខិកោ *តទ្ធិតនាមបទឈ្មោះទិព្វតិតទ្ធិតហើយជាវិសេសនៈរបស់ធិតោ។* *លិង្គត្ថៈ ។*

📖❋❋

***វិទិតតទ្ធិត*** ឧ. លោកេ វិទិតោ = លោកិកោ (ធម្មោ) ។

**ប្រែលោតប្រយោគ**

យោ ធម្មោ *វីធម៌ឯណា* វិទិតោ *ប្រាកដហើយ* លោកេ *ក្នុងលោក* សោ ធម្មោ *វីធម៌នោះ* លោកិកោ *ឈ្មោះលោកិកោ* ធម្មោ *វីធម៌* លោកិកោ *ប្រាកដហើយក្នុងលោក ។*

**សម្ពន្ធ**

យោ *វិសេសនៈរបស់ធម្មោ។* *លិង្គត្ថៈ,* លោកេ *វេសយិកាធារៈក្នុង* វិទិតោ។ *វិសេសនៈរបស់ធម្មោ,* សោ *វិសេសនៈរបស់ធម្មោ,* លោកិកោ *សញ្ញាវិសេសនៈរបស់ធម្មោ។* *សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* លោកិកោ *តទ្ធិតនាមបទឈ្មោះវិទិតតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់* ធម្មោ។ *លិង្គត្ថៈ ។*

📖❋❋

***សំវត្តតិតទ្ធិត*** ឧ. លោកាយ សំវត្តតីតិ = លោកិកោ (ជនោ) ។

## ប្រែលោតប្រយោគ

យោ ធម្មោ *វីធម៌ឯណា* សំវត្តតិ *ប្រព្រឹត្តទៅព្រម* លោកាយ *ដើម្បីសត្វលោក* ឥតិ *ព្រោះហេតុដូច្នោះ* សោ ធម្មោ *វីធម៌នោះ* លោកិកោ *ឈ្មោះលោកិកោ* ធម្មោ *វីធម៌* លោកិកោ *ប្រព្រឹត្តទៅព្រមដើម្បីសត្វលោក* ។

## សម្ពន្ធ

យោ *វិសេសនៈរបស់ធម្មោ ៗ សយកត្តាក្នុងសំវត្តតិៗ អាខ្យាតបទកត្តុវាចកៈ,* លោកាយ *សម្បទានក្នុងសំវត្តតិ,* ឥតិ*សព្វហេតុត្ថវាចកៈ,* សោ *វិសេសនៈរបស់*ធម្មោ, លោកិកោ *សញ្ញាវិសេសនៈរបស់ធម្មោៗ សញ្ញីវិសេសយៈហើយជា* (*និង*ជា) *លិង្គត្ថៈ,* លោកិកោ *តទ្ធិតនាមបទឈ្មោះវត្តតិតទ្ធិត ហើយជាវិសេសនៈរបស់ធម្មោៗ លិង្គត្ថៈ* ។

***រាគតទ្ធិតឬវត្តតទ្ធិត*** ឧ. កសាវេន រត្តំ (វត្ថំ) = កាសាវំ ។

## ប្រែលោតប្រយោគ

យំ វត្ថំ *វីសំពត់ឯណា* រត្តំ *ដែលជនជ្រលក់ហើយ* កសាវេន *ដោយទឹកចត់* តំ វត្ថំ *វីសំពត់នោះ* កាសាវំ *ឈ្មោះកាសាវំ* វត្ថំ *វីសំពត់* កាសាវំ

*ដែលជនជ្រលក់ហើយដោយទឹកចត់ ។*

## សម្ពន្ធ

យំ *វិសេសនៈរបស់វត្ថំ ។ លិង្គត្ថៈ,* កសាវេន *ករណៈក្នុងវត្ថុំ។ វិសេសនៈរបស់វត្ថំ,* តំ *វិសេសនៈរបស់វត្ថំ,* កាសាវំ *សញ្ញាវិសេសនៈរបស់វត្ថំ។ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* កាសាវំ *តទ្ធិតនាមបទឈ្មោះពាគតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់វត្ថំ ។ លិង្គត្ថៈ ។*

📖❋❋

***ឥទំតទ្ធិត*** ឧ. *សូករស្ស* ឥទំ (មំសំ) = សោករំ ។

## ប្រែលោតប្រយោគ

ឥទំ មំសំ *វីសាច់នេះ សូករស្ស នៃជ្រូក* តំ មំសំ *វីសាច់នោះ* សោករំ *ឈ្មោះសោករំ* មំសំ *វីសាច់* សោករំ *នេះនៃជ្រូក ។ ឬថា* ឥទំ មំសំ *វីសាច់នេះ* មំសំ *ជាសាច់ សូករស្ស នៃជ្រូក* តំ មំសំ *វីសាច់នោះ* សោករំ *ឈ្មោះសោករំ* មំសំ *វីសាច់* សោករំ *នេះជាសាច់នៃជ្រូក ។*

## សម្ពន្ធ

ឥទំ *វិសេសនៈរបស់* មំសំ ។ *លិង្គត្ថៈ សូករស្ស សាមិសម្ពន្ធក្នុង* ឥទំ មំសំ តំ *វិសេសនៈរបស់មំសំ,* សោករំ *សញ្ញាវិសេសនៈរបស់មំសំ។ សញ្ញីវិសេសយៈ*

*ហើយជា* (និង*ជា*) *លិង្គត្ថៈ*, សោករំ *តទ្ធិតនាមបទឈ្មោះឥទំតទ្ធិតហើយជា* (និង*ជា*) *វិសេសនៈរបស់*មំសំ ៗ *លិង្គត្ថៈ* ។ ឬថា *សូករស្ស សាមិសម្ពន្ធក្នុង* មំសំ ៗ *វិសេសនៈរបស់*ឥទំ មំសំ, ឥទំ *វិសេសនៈរបស់*មំសំ ៗ *លិង្គត្ថៈ*, តំ *វិសេសនៈរបស់*មំសំ, សោករំ *សញ្ញាវិសេសនៈរបស់*មំសំ ៗ *សញ្ញីវិសេសយៈ ហើយជា*(និង*ជា*) *លិង្គត្ថៈ*, សោករំ *តទ្ធិតនាមបទឈ្មោះឥទំតទ្ធិតហើយជា* (និង*ជា*) *វិសេសនៈរបស់*មំសំ ៗ *លិង្គត្ថៈ* ។

**ភវតទ្ធិត** ឧ. ឱទុម្ពរស្ស អវិទូរេ ភវំ (វិមានំ) = ឱទុម្ពរំ ។

ឱទុម្ពរេ ភវំ = ឱទុម្ពរំ (វិមានំ) ។

### ប្រែលោតប្រយោគ

យំ វិមានំ *វិមានឯណា* ភវំ *កើត ឬ មាន* អវិទូរេ *ក្នុងទីជិត* ឱទុម្ពរស្ស *នៃដើមល្វា* តំ វិមានំ *វិមាននោះ* ឱទុម្ពរំ *ឈ្មោះឱទុម្ពរំ* វិមានំ *វិមាន* ឱទុម្ពរំ *កើតឬមានក្នុងទីជិតនៃដើមល្វា* ។

យំ វិមានំ *វិមានឯណា* ភវំ *មាន* ឱទុម្ពរេ *ជិតដើមល្វា* តំ វិមានំ *វិមាននោះ* ឱទុម្ពរំ *ឈ្មោះឱទុម្ពរំ* វិមានំ *វិមាន* ឱទុម្ពរំ *មានជិតដើមល្វា* ។

## សម្ពន្ធ

យំ *វិសេសនៈរបស់*វិមានំៗ *លិង្គត្ថៈ*, ឱទុម្ពរស្ស *សាមិសម្ពន្ធក្នុងអវិទូរេៗ វេសយិកាធារៈក្នុងភវិៗ វិសេសនៈរបស់*វិមានំ, តំ *វិសេសនៈរបស់*វិមានំ, ឱទុម្ពរំ *សញ្ញាវិសេសនៈរបស់*វិមានំៗ *សញ្ញីវិសេសយៈហើយជា* (និង*ជា*) *លិង្គត្ថៈ*, ឱទុម្ពរំ *តទ្ធិតនាមបទឈ្មោះកវតទ្ធិតហើយជា* (និង*ជា*) *វិសេសនៈរបស់*វិមានំៗ *លិង្គត្ថៈ* ។

យំ *វិសេសនៈរបស់*វិមានំៗ *លិង្គត្ថៈ*, ឱទុម្ពរេ *សមីបាធារៈក្នុងភវិៗ វិសេសនៈរបស់*វិមានំ, តំ *វិសេសនៈរបស់*វិមានំ, ឱទុម្ពរំ *សញ្ញាវិសេសនៈរបស់*វិមានំៗ *សញ្ញីវិសេសយៈហើយជា* (និង*ជា*) *លិង្គត្ថៈ*, ឱទុម្ពរំ *តទ្ធិតនាមបទឈ្មោះកវតទ្ធិតហើយជា* (និង*ជា*) *វិសេសនៈរបស់*វិមានំៗ *លិង្គត្ថៈ* ។

***ជាតតទ្ធិត*** ឧ. មគធេ ជាតោ = មាគធោ (ជនោ) ។

## ប្រែលោតប្រយោគ

យោ ជនោ *រីជនឯណា* ជាតោ *កើតហើយ* មគធេ *ក្នុងដែនមគធៈ* សោ ជនោ *រីជននោះ* មាគធោ *ឈ្មោះមាគធោ* ជនោ *រីជន* មាគធោ *កើតហើយក្នុងដែនមគធៈ* ។

## សម្ពន្ធ

យោ *វិសេសនៈរបស់ជិតោ។* លិង្គត្ថៈ, មគធេ *វេសយិកាធារៈក្នុង* ជាតោ។ *វិសេសនៈរបស់ជិតោ,* សោ *វិសេសនៈរបស់ជិតោ* មាគធោ *សញ្ញាវិសេសនៈ* *របស់ជិតោ។* *សញ្ញីវិសេសយៈហើយជា* (និង៍ជា) *លិង្គត្ថៈ* មាគធោ *តទ្ធិតនាមបទឈ្មោះជាតតទ្ធិតហើយជា វិសេសនៈរបស់ជិតោ។ លិង្គត្ថៈ ។*

📖❋❋

***អាគតតទ្ធិត ៦.*** មគធស្មា អាគតោ = មាគធោ (ជិតោ) ។

## ប្រែលោតប្រយោគ

យោ ជិតោ *រីជនឯណា* អាគតោ *មកហើយ* មគធស្មា *អំពីដែនមគធៈ* សោ ជិតោ *រីជននោះ* មាគធោ *ឈ្មោះមាគធោ* ជិតោ *រីជន* មាគធោ *មក* *ហើយអំពីដែនមគធៈ ។*

## សម្ពន្ធ

យោ *វិសេសនៈរបស់ជិតោ។* *លិង្គត្ថៈ,* មគធស្មា *អបាទានក្នុងអាគតោ។* *វិសេសនៈរបស់ជិតោ,* សោ *វិសេសនៈរបស់ជិតោ,* មាគធោ *សញ្ញាវិសេសនៈ* *របស់ជិតោ។* *សញ្ញីវិសេសយៈហើយជា* (និង៍ជា) *លិង្គត្ថៈ,* មាគធោ *តទ្ធិត* *នាមបទឈ្មោះអាគតតទ្ធិតហើយជា* (និង៍ជា) *វិសេសនៈរបស់ជិតោ។ លិង្គត្ថៈ។*

📖❋❋

***និយុត្តតទ្ធិត*** ឧ. កត្តិកាយ និយុត្តោ = កត្តិកោ (មាសោ) ។

**ប្រែលោតប្រយោគ**

យោ មាសោ *រីខែឯណា* និយុត្តោ *ប្រកបហើយ* កត្តិកាយ *ដោយកត្តិកាឫក្ស* សោ មាសោ *រីខែនោះ* កត្តិកោ *ឈ្មោះកត្តិកោ* មាសោ *រីខែ* កត្តិកោ *ប្រកបហើយដោយកត្តិកាឫក្ស* = (*ខែកត្តិក*) ។

**សម្ពន្ធ**

យោ *វិសេសនៈរបស់*មាសោៗ *លិង្គត្ថៈ*, កត្តិកាយ *ករណៈក្នុង*និយុត្តោៗ *វិសេសនៈរបស់*មាសោ, សោ *វិសេសនៈរបស់*មាសោ, កត្តិកោ *សញ្ញាវិសេសនៈរបស់*មាសោៗ *សញ្ញីវិសេសយៈហើយជា* (*និង*ជា) *លិង្គត្ថៈ*, កត្តិកោ *តទ្ធិតនាមបទឈ្មោះនិយុត្តតទ្ធិតហើយជា* (*និង*ជា) *វិសេសនៈរបស់*មាសោៗ *លិង្គត្ថៈ* ។

📖❋❋

***ទេវតាតទ្ធិត*** ឧ. ពុទ្ធោ អស្ស ទេវតាតិ = ពុទ្ធោ (ជនោ) ។

**ប្រែលោតប្រយោគ**

ពុទ្ធោ *រីព្រះពុទ្ធ* ទេវតា *ជាទេវតា* អស្ស ជនស្ស *នៃជននេះ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *រីជននោះ* ពុទ្ធោ *ឈ្មោះពុទ្ធោ* ជនោ *រីជន* ពុទ្ធោ *មានព្រះពុទ្ធជាទេវតា* ។

## សម្ពន្ធ

អស្ស *វិសេសនៈរបស់ផលស្ស ៗ សាមិសម្ពន្ធក្នុងទេវតា ៗ នានាលិង្គត្ថ វិសេសនៈរបស់ពុទ្ធោៗ លិង្គត្ថៈ,* **ឥតិ** *សព្វហេតុត្ថវាចកៈ,* សោ *វិសេសនៈរបស់* ជនោ, ពុទ្ធោ *សញ្ញាវិសេសនៈរបស់ជនោៗ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* ពុទ្ធោ *តទ្ធិតនាមបទឈ្មោះទេវតាតទ្ធិតហើយជា* (និងជា) *វិសេសនៈ របស់ជនោៗ លិង្គត្ថៈ ។*

📖❈❈

***អវេច្ចធីតេតទ្ធិតឬអធីតេតទ្ធិត*** ឧ. សំវច្ឆរំ អវេច្ច អធីតេតិ = សំវច្ឆរោ (ជនោ) ។ និមិត្តមធីតេ ជានាតិ វា = នេមិត្តោ (ជនោ)។

### ប្រែលោតប្រយោគ

យោ ជនោ *រីជនឯណា* អវេច្ច *ពិចារណាហើយ* អធីតេ *រៀន* សំវច្ឆរំ *នូវឆ្នាំ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *រីជននោះ* សំវច្ឆរោ *ឈ្មោះ សំវច្ឆរោ* ជនោ *រីជន* សំវច្ឆរោ *ពិចារណាហើយរៀននូវឆ្នាំ ។*

យោ ជនោ *រីជនឯណា* អធីតេ *រៀន* ជានាតិ វា *ឬចេះ* និមិត្តំ *នូវ និមិត្ត* សោ ជនោ *រីជននោះ* នេមិត្តោ *ឈ្មោះនេមិត្តោ* ជនោ *រីជន* នេមិត្តោ *រៀន ឬចេះនូវនិមិត្ត ។*

## សម្ពន្ធ

យោ *វិសេសនៈរបស់ផលោៗ សយកត្តាក្នុងអធីតេៗ អាខ្យាតបទកត្តុវាចកៈ* អវេច្ច *បុព្វកាលកិរិយាក្នុងអធីតេ,* សំវិច្ចរំ *អវុត្តកម្មក្នុងអធីតេ,* ឥតិ *សព្ទហេតូត្ថវាចកៈ* សោ *វិសេសនៈរបស់ផលោ,* សំវិច្ចរោ *សញ្ញាវិសេសនៈរបស់ផលោៗ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* សំវិច្ចរោ *តទ្ធិតនាមបទឈ្មោះអវេច្ចធីតេតទ្ធិតឬឈ្មោះអធីតេតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់ផលោៗ លិង្គត្ថៈ ។*

យោ *វិសេសនៈរបស់ផលោៗ សយកត្តាក្នុងអធីតេ* ជាតាតិ វា, *វាសព្ទបទវិកប្បៈក្នុង*ជាតាតិ, អធីតេក្តី ជាតាតិក្តី *អាខ្យាតបទកត្តុវាចកៈ,* និមិត្តំ *អវុត្តកម្មក្នុងអធីតេ* ជាតាតិ, សោ *វិសេសនៈរបស់ផលោ,* នេមិត្តោ *សញ្ញាវិសេសនៈរបស់ផលោៗ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថ,* នេមិត្តោ *តទ្ធិតនាមបទឈ្មោះអធីតេ ឬ ជានាតិតទ្ធិត ហើយជា* (និងជា) *វិសេសនៈរបស់*ផលោៗ *លិង្គត្ថៈ*ៗ

***វិសយតទ្ធិត*** ឧ. កុត្តានំ វិសយោ ទេសោ = កុត្តោ ។

### ប្រែលោតប្រយោគ

យោ ទេសោ *វិប្រទេសឯណា* វិសយោ *ជាទីនៅ* កុត្តានំ *នៃសត្វក្រៀលទាំងឡាយ* សោ ទេសោ *វិប្រទេសនោះ* កុត្តោ *ឈ្មោះកុន្តោ* ទេសោ *វិប្រទេស* កុត្តោ *ជាទីនៅនៃសត្វក្រៀល ។*

### សម្ពន្ធ

យោ *វិសេសនៈរបស់ទេសោៗ លិង្គត្ថៈ,* កុត្តានំ *សាមិសម្ពន្ធក្នុងវិសយោៗ វិសេសនៈរបស់ទេសោ,* សោ*វិសេសនៈរបស់ទេសោ,* កុត្តោ *សញ្ញាវិសេសនៈរបស់ទេសោៗ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* កុត្តោ *តទ្ធិតនាមបទឈ្មោះវិសយតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់ទេសោៗ លិង្គត្ថៈ ។*

📖❋❋

***សន្ទិតទ្ធិត*** ឧ. ឱទុម្ពរា អស្មឹ (បទេសេ) សន្តិ = ឱទុម្ពរោ ។

### ប្រែលោតប្រយោគ

ឱទុម្ពរា *រីដើមល្វាទាំងឡាយ* សន្តិ *មាន* អស្មឹ បទេសេ *ក្នុងប្រទេសនេះ* សោ បទេសោ *រីប្រទេសនោះ* ឱទុម្ពរោ *ឈ្មោះឱទុម្ពរោ* បទេសោ *រីប្រទេស ឱទុម្ពរោ មានដើមល្វា ។*

### សម្ពន្ធ

ឱទុម្ពរា *សយកត្តាក្នុងសន្តិៗ អាខ្យាតបទកត្តុវាចកៈ,* អស្មឹ *វិសេសនៈរបស់បទេសេៗ វេសយិកាធារៈក្នុងសន្តិ,* សោ *វិសេសនៈរបស់បទេសោ* ឱទុម្ពរោ *សញ្ញាវិសេសនៈរបស់បទេសោៗ សញ្ញីវិសេសយៈហើយជា* (និងជា) *លិង្គត្ថៈ,* ឱទុម្ពរោ *តទ្ធិតនាមបទឈ្មោះសន្ទិតទ្ធិតហើយជា* (និងជា) *វិសេសនៈរបស់បទេសោៗ លិង្គត្ថៈ ។*

📖❋❋

***និព្វត្តតទ្ធិត*** ឧ. សាគរេហិ (រាជកុមារេហិ) និព្វត្តោតិ = សាគរោ (សមុទ្ទោ) ។

## ប្រែលោតប្រយោគ

យោ សមុទ្ទោ *វីសមុទ្រឯណា* និព្វត្តោ *កើតហើយ* រាជកុមារេហិ *ដោយសារព្រះរាជកុមារទាំងឡាយ* សាគរេហិ *ជាបុត្រនៃស្តេចសាគរ* សោ សមុទ្ទោ *វីសមុទ្រនោះ* សាគរោ *ឈ្មោះសាគរោ* សមុទ្ទោ *វីសមុទ្រ* សាគរោ *កើតហើយដោយសារព្រះរាជកុមារជាបុត្រនៃស្តេចសាគរ ។*

## សម្ពន្ធ

យោ *វិសេសនៈរបស់សមុទ្ទោ* ៗ *លិង្គត្ថៈ*, សាគរេហិ *វិសេសនៈរបស់* រាជកុមារេហិៗ *តតិយាវិសេសនៈក្នុងនិព្វត្តោៗ វិសេសនៈរបស់សមុទ្ទោ*, សោ *វិសេសនៈរបស់សមុទ្ទោ*, សាគរោ *សញ្ញាវិសេសនៈរបស់សមុទ្ទោៗ សញ្ញីវិសេសយៈហើយជាលិង្គត្ថៈ*, សាគរោ *តទ្ធិតនាមបទឈ្មោះនិព្វត្តតទ្ធិត ហើយជាវិសេសនៈរបស់សមុទ្ទោៗ លិង្គត្ថៈ។*

***និវាសតទ្ធិត*** ឧ. មគធោ អស្សូ និវាសោតិ = មាគធោ (ជនោ) ។

## ប្រែលោតប្រយោគ

មគធោ *វីដែនមគធៈ* និវាសោ *ជាទីនៅអាស្រ័យ* អស្សូ ជនស្ស

*នៃជននេះ* ឥតិ *ព្រោះហេតុដូច្នោះ* សោ ជនោ *រីជននោះ* មាគធោ *ឈ្មោះមាគធោ* ជនោ *រីជន* មាគធោ *មានដែនមគធៈជាទីនៅអាស្រ័យ ។*

## សម្ពន្ធ

អស្ស *វិសេសនៈរបស់ជនស្សៗ សាមិសម្ពន្ធក្នុងនិវាសោៗ វិសេសនៈរបស់មគធោៗ លិង្គត្ថៈ,* ឥតិ*សព្វហេតុត្ថវាចកៈ,* សោ *វិសេសនៈរបស់ជនោ* មាគធោ *សញ្ញាវិសេសនៈរបស់ជនោៗ សញ្ញីវិសេសយៈហើយជាលិង្គត្ថៈ* មាគធោ *តទ្ធិតនាមបទឈ្មោះនិវាសតទ្ធិត ហើយជាវិសេសនៈរបស់ជនោៗ លិង្គត្ថៈ ។*

📖❋❋

***ឥស្សរតទ្ធិត*** ឧ. មថុរាយ ឥស្សរោ = មាថុរោ (ជនោ) ។

## ប្រែលោតប្រយោគ

យោ ជនោ *រីជនឯណា* ឥស្សរោ *ជាឥស្សរៈ* មថុរាយ *ក្នុងនគរមថុរា* សោ ជនោ *រីជននោះ* មាថុរោ *ឈ្មោះមាថុរោ* ជនោ *រីជន* មាថុរោ *ជាឥស្សរៈក្នុងនគរមថុរា ។*

## សម្ពន្ធ

យោ *វិសេសនៈរបស់* ជនោៗ *លិង្គត្ថៈ* មថុរាយ[១] ភុម្មត្ថឆដ្ឋី ឬ ភុម្មត្ថ

---

(១) មថុរា នេះ បើជាសត្តមីវិភត្តិថា មថុរាយ វេសយិកាធារៈក្នុងឥស្សរោ ។

*សាមិវចនៈក្នុងឥស្សរោ។* *វិសេសនៈរបស់ជនោ,* សោ *វិសេសនៈរបស់ជនោ* មាបុរោ *សញ្ញាវិសេសនៈរបស់ជនោ។ សញ្ញីវិសេសយៈហើយជាលិង្គត្ថៈ,* មាបុរោ *តទ្ធិតនាមបទឈ្មោះឥស្សរតទ្ធិតហើយជាវិសេសនៈរបស់ជនោ។ លិង្គត្ថៈ ។*

📖❋❋

***ជាតតទ្ធិត*** ឧ. បុរេ ជាតោ = បុរិមោ (ជនោ) ។

មនុស្សជាតិយា ជាតោ = មនុស្សជាតិយោ (សត្តោ) ។

**ប្រែលោតប្រយោគ**

យោ ជនោ *រីជនឯណា* ជាតោ *កើតហើយ* បុរេ *ក្នុងកាលមុន* សោ ជនោ *រីជននោះ* បុរិមោ *ឈ្មោះបុរិមោ* ជនោ *រីជន* បុរិមោ *កើតហើយក្នុងកាលមុន ។*

